ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION, YOUTH AND SPORT

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់

# THE PROCESS OF PREPARING BUDGET PLAN OF C.P. CAMBODIA CO., LTD

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION, YOUTH AND SPORT

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

## ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់

THE PROCESS OF PREPARING BUDGET PLAN OF
C.P. CAMBODIA CO., LTD

គ្រូណែនាំ៖ ហ៊ីង សុខលីដា

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទ៖ ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី ធី ខេមបូឌា ចំកាត់**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ហ៊ឹង សុខលីដា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យគឺជាជំនាញដែលមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យ ហិរញ្ញវត្ថុ និងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យតាំងពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុនផលិតកម្ម។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះនឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការមួយនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងទាំងពាក្យពេចន៍ អក្ខរាវិរុទ្ធ អត្ថន័យ និងខ្លឹមសារដែលអាចកើតមានឡើងដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនាដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



**ម៉ូត អាំមីណាស់**
ID: B22/2289



**លីវ ម៉ូលីកា**
ID: B22/1804



**ផេន ថាស្លា**
ID: B22/1710



**សុខ វណ្ណានិត**
ID: B22/2254



**អយ ឆេងស៊ីម**
ID: B22/719

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជម្រុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្តាលោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **ហ៊ីង សុខលីដា** ជាគ្រូដឹកនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។ សូមគោរពថ្លែងអំណរគុណដល់លោកគ្រូ អ្នកគ្រូ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អំណះអំណាង**

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ “**ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់**” នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ..ពុធ..៨កើត.. ខែ..កត្តិក..ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី..២៨..ខែ..តុលា.. ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

អ៊ុត សាំមីណាស់

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ក្នុងបរិបទសេដ្ឋកិច្ចកម្ពុជា ដែលកំពុងរីកចម្រើនលើវិស័យក្រុមហ៊ុនផលិតកម្ម គឺជាឯកតាអាជីវកម្ម ដែលមានសារសំខាន់យ៉ាងខ្លាំងក្នុងការជម្រុញសេដ្ឋកិច្ចជាតិ តាមរយៈការផ្តល់ការងារ ការផលិតផលិតផល និងសេវាកម្មផ្សេងៗ។ ដើម្បីធានាថាការប្រតិបត្តិការរបស់ក្រុមហ៊ុនអាចសម្រេចបានល្អ និងទទួលបានប្រាក់ចំណេញ ការរៀបចំគម្រោងថវិកាជាដំណើរការសំខាន់មួយ ដែលអាចជួយឱ្យគ្រប់គ្រងការចំណាយ និងប្រាក់ចំណូលបានយ៉ាងមានប្រសិទ្ធភាព។ គម្រោងថវិកា គឺជាឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនអាចរំពឹងនឹងប្រាក់ចំណូល និងចំណាយក្នុងអនាគត ដើម្បីបំពេញគោលដៅរបស់ខ្លួន។

ក្នុងការវិភាគចំណុចខ្លាំងនៃការរៀបចំគម្រោងថវិកា អាចឱ្យយើងឃើញថា ក្រុមហ៊ុនដែលមានប្រព័ន្ធគ្រប់គ្រងថវិកាដែលប្រសើរមានសមត្ថភាពក្នុងការប្រមូលទិន្នន័យហិរញ្ញវត្ថុបានលឿន និងច្បាស់លាស់ ជួយសម្រួលការទស្សន៍ទាយ និងការធ្វើសេចក្តីសម្រេចលើការវិនិយោគ ឬការចំណាយ។ ក្រុមហ៊ុនដូចជា C.P. Cambodia Co., Ltd បានបង្ហាញពីសមត្ថភាពក្នុងការរៀបចំថវិកាដោយប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាទំនើប និងការចូលរួមពីផ្នែកជាច្រើន ដើម្បីធានាថាការប្រើប្រាស់ធនធានត្រូវបានសម្របសម្រួលតាមគោលបំណងអាជីវកម្ម។ ការមានគោលនយោបាយច្បាស់លាស់ ការចាត់ចែងសិទ្ធិ ភារកិច្ចរបស់បុគ្គលិក និងការត្រួតពិនិត្យលើការចំណាយជាប្រចាំ ជាធាតុបង្កើនប្រសិទ្ធភាពរបស់គម្រោងថវិកាឱ្យកាន់តែមានប្រសិទ្ធភាព។

ប៉ុន្តែទោះជាយ៉ាងណា ក៏មានចំណុចខ្សោយមួយចំនួនដែលត្រូវបានគេរកឃើញនៅក្នុងក្រុមហ៊ុនមួយចំនួនក្នុងប្រទេសកម្ពុជា។ ចំណុចទាំងនេះរួមមានការខ្វះការបណ្តុះបណ្តាលដល់បុគ្គលិកអំពីវិធីសាស្ត្ររៀបចំថវិកា ការប្រមូលទិន្នន័យមិនទាន់មានប្រព័ន្ធត្រឹមត្រូវ កង្វះការវិភាគទីផ្សារដែលមានប្រសិទ្ធភាព និងការខ្វះធនធានហិរញ្ញវត្ថុសម្រាប់ឧបទ្ទវហេតុ។ កត្តាទាំងនេះអាចប៉ះពាល់ដល់ភាពជោគជ័យនៃគម្រោងថវិកា និងនាំឱ្យមានការបាត់បង់ឱកាសនៃអាជីវកម្ម។ ពិសេសស្ថានភាពសេដ្ឋកិច្ចពិភពលោក និងបញ្ហាផ្សេងៗជាច្រើនក៏អាចមានឥទ្ធិពលដល់ការអនុវត្តន៍នៃថវិកាផងដែរ ប្រសិនបើក្រុមហ៊ុនមិនមានយុទ្ធសាស្ត្រជាក់លាក់ក្នុងការជួយឱ្យគម្រោងថវិកាអាចបន្តប្រតិបត្តិការបាននៅក្នុងស្ថានភាពលំបាកទាំងនោះ។

ដោយសារកត្តាខាងលើនេះ ក្រុមហ៊ុនទូទៅនៅកម្ពុជា គួរបង្កើនសមត្ថភាពក្នុងការគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ ដោយការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ការបណ្តុះបណ្តាលបុគ្គលិកឱ្យមានជំនាញផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ការរៀបចំគម្រោងថវិកាបម្រុងសម្រាប់ការប្រែប្រួលអនាគត និងការផ្គត់ផ្គង់ទិន្នន័យទីផ្សារដោយមានប្រភពច្បាស់លាស់។ ជាធម្មតាការរៀបចំថវិកាដែលមានគុណភាពខ្ពស់ មិនត្រឹមតែជួយការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែបង្កើនភាពជឿជាក់របស់វិនិយោគិន និងបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារផងដែរ។

ជាសរុបគម្រោងថវិកា ជាឧបករណ៍គ្រប់គ្រងដ៏មានសារៈសំខាន់សម្រាប់ក្រុមហ៊ុនទាំងឡាយ។ ការយល់ដឹងពីចំណុចខ្លាំង និងចំណុចខ្សោយនៃការរៀបចំគម្រោងថវិកា អាចជួយឱ្យក្រុមហ៊ុនសម្រេចបាននូវគោលបំណងនានា និងជៀសវាងហានិភ័យសេដ្ឋកិច្ច។ ដោយការអនុវត្តយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការរៀបចំ និងគ្រប់គ្រងថវិកា ក្រុមហ៊ុននៅកម្ពុជា អាចបង្កើនសមត្ថភាពក្នុងការប្រកួតប្រជែង និងជម្រុញការរីកចម្រើននាពេលអនាគតបានយ៉ាងរឹងមាំ។

# មាតិកា

**ទំព័រ**


អារម្ភកថា ........ i
រចនាសម្ព័ន្ធ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ vi
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា........ vi


## ជំពូកទី ១
## សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
១.៣ គោលបំណងនៃការស្រាវជ្រាវ........ ២
១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំ និងដែនកំណត់ ........ ២
១.៤.២ វិសាលភាព........ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ........ ៣
១.៥.១ ការបកស្រាយសំណួរទី១........ ៣
១.៥.២ ការបកស្រាយសំណួរទី២ ........ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........ ៤


## ជំពូកទី ២
## រំលឹកទ្រឹស្តី


២.១ លក្ខណៈទូទៅនៃការរៀបចំគម្រោងថវិកា........ ៥
២.១.១ និយមន័យ........ ៥
២.១.២ ប្រវត្តិនៃការរៀបចំគម្រោងថវិកា ........ ៦
២.១.៣ ទ្រឹស្តីនៃការធ្វើគម្រោងថវិកា........ ៧
២.២ នីតិវិធីក្នុងការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុនផលិតកម្ម ........ ៧
២.៣ អត្ថប្រយោជន៍នៃការរៀបចំគម្រោងថវិកា........ ៩
២.៣.១ អត្ថប្រយោជន៍នៃការរៀបចំគម្រោងថវិកាចំពោះក្រុមហ៊ុន ........ ៩
២.៣.២ អត្ថប្រយោជន៍នៃការរៀបចំគម្រោងថវិកាចំពោះមជ្ឈដ្ឋានខាងក្រៅ ........ ១០

២.៣.៣ ការវិភាគផលប៉ះពាល់នៃការរៀបចំគម្រោងថវិកា.......................................... ១០

## ជំពូកទី ៣

## លទ្ធផលនៃការស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅនៃក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់........................................ ១១
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់ ........................................ ១១
៣.១.២ ចក្ខុវិស័យ បេសកកម្ម ការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់.............. ១៥
ក. ចក្ខុវិស័យ ........................................ ១៥
ខ. បេសកកម្ម........................................ ១៥
គ. ការប្តេជ្ញាចិត្ត........................................ ១៥
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី នឹងភារកិច្ច របស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់ ...... ១៦
ក. រចនាសម្ព័ន្ធការគ្រប់គ្រង ........................................ ១៦
ខ. តួនាទី និងភារកិច្ច ........................................ ១៨
៣.២ នីតិវិធីនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់ ........................ ២០
៣.២.១ ការកំណត់គោលដៅ ........................................ ២០
៣.២.២ ការដាក់ផែនការ និងការប៉ាន់ស្មានចំណាយ ........................................ ២១
៣.២.៣ ការស្នើសុំ និងអនុម័ត........................................ ២៣
៣.២.៤ ការចាត់ចែង........................................ ២៤
៣.២.៥ ការត្រួតពិនិត្យលើផែនការ និងការអនុវត្តន៍........................................ ២៥
៣.៣ អត្ថប្រយោជន៍ក្នុងដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់ . ២៥
៣.៣.១ អត្ថប្រយោជន៍ចំពោះក្រុមហ៊ុន ........................................ ២៦
៣.៣.២ អត្ថប្រយោជន៍ចំពោះមជ្ឈដ្ឋានខាងក្រៅ ........................................ ២៧

## ជំពូកទី ៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង........................................ ២៨
៤.២ ការវិភាគលើចំណុចខ្សោយ ........................................ ៣៩

## ជំពូកទី ៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........................................ ៣០
៥.២ ការផ្តល់អនុសាសន៍ ........................................ ៣០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី ១
# សេចក្ដីផ្ដើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននេះប្រទេសកម្ពុជា គឺជាប្រទេសមួយដែលគេចាត់ទុកថាជាប្រទេសដែលកំពុងរីកចម្រើន និងមានការអភិវឌ្ឍលើគ្រប់វិស័យនៅក្នុងចំណោមបណ្ដាប្រទេសផ្សេងៗទៀតនៅលើសកលលោក។ ស្របពេលដែលការធ្វើសមាហរ័ណកម្ម បានចូលទៅក្នុងពិភពលោកទាំងមូល និងការចាប់ផ្ដើមបើកចំហរនូវសេដ្ឋកិច្ចទីផ្សាររួម បូកបញ្ចូលនឹងការទំនាក់ទំនងពាណិជ្ជកម្មយ៉ាងល្អខ្ជាប់ខ្ជួនជាមួយប្រទេសនានានៅលើពិភពលោក បានជួយជម្រុញឱ្យការវិនិយោគនៅក្នុងប្រទេសកម្ពុជាកាន់តែមានការកើនឡើងលើវិស័យជាច្រើនរួមមាន វិស័យកសិកម្ម ពាណិជ្ជកម្ម វិស័យឧស្សាហកម្ម ជាពិសេសគឺទៅលើវិស័យផលិតកម្មរបស់ក្រុមហ៊ុនផលិតកម្មដែលមានការកើនឡើងជារៀងរាល់ថ្ងៃ។ យើងសង្កេតឃើញថាសព្វថ្ងៃនេះ លំហូរនៃអ្នកវិនិយោគទុនបរទេស និងក្នុងប្រទេស គឺបានចូលរួមបណ្ដាក់ទុនវិនិយោគទៅលើផលិតកម្មជាច្រើននៅក្នុងប្រទេស ជាហេតុធ្វើឱ្យប្រទេសកម្ពុជាកាន់តែមានភាពរីកចម្រើនគួរឱ្យកត់សម្គាល់។ ទន្ទឹមនឹងការកើនឡើងនៃការបង្កើតផលិតកម្មនេះដែរ ក៏មានផលិតកម្មជាច្រើនទទួលជោគជ័យ និងផលិតកម្មមួយចំនួនទៀតក៏ទទួលរងនូវហានិភ័យខ្ពស់ទៅលើការគ្រប់គ្រងអាជីវកម្ម និងហិរញ្ញវត្ថុផងដែរ។

ដោយសារតែឃើញអំពីបញ្ហាខាងលើនេះហើយ ទើបគេអាចនិយាយបានថាការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពសម្រាប់រក្សាមុខជំនួញ គឺជាហេតុផលដ៏សំខាន់ក្នុងការទប់ទល់ការបរាជ័យក្នុងការប្រកបអាជីវកម្ម ហើយដើម្បីធ្វើឱ្យមានការទុកចិត្តពីបណ្ដាវិនិយោគក្នុងវិស័យផលិតកម្មនីមួយៗ ត្រូវមានការរៀបចំរចនាសម្ព័ន្ធដើម្បីការបង្កើតឱ្យមានគោលនយោបាយការគ្រប់គ្រង ការរៀបចំផែនការ ការវិភាគ និងជាពិសេសបំផុត គឺការថែរក្សាទុកឯកសារ ការទទួលស្គាល់ ការកត់ត្រាទិន្នន័យដែលគេប្រមូលមកតាមវិធីសាស្ត្រផ្សេងៗគ្នា។ ក្នុងនោះដែរ ប្រសិនបើការមិនមានការរៀបចំផែនការហិរញ្ញវត្ថុឱ្យបានល្អិតល្អន់នោះទេ វានឹងជះឥទ្ធិពលដល់ការរៀបចំផែនការផលិតកម្មមិនបានល្អ ហើយការរៀបចំផែនការមិនបានល្អវាក៏ធ្វើឱ្យការគ្រប់គ្រងមិនមានប្រសិទ្ធភាព និងមិនដល់គោលដៅដែលបានគ្រងទុកនាំឱ្យបរាជ័យ និងឈានដល់ការបិទទ្វារផងដែរ។ នេះជាហេតុដែលអ្នកវិនិយោគនីមួយៗមុននិង វិនិយោគទុនផ្ទាល់ខ្លួនរបស់ពួកគេត្រូវដឹងអំពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុថាមានតុល្យភាពហើយឬនៅ។ បណ្ដាស្ថាប័ន ឬក្រុមហ៊ុនផ្សេងៗតែងតែមានភាពខ្លាំង និងភាពខ្សោយខុសៗគ្នាទៅតាមការគ្រប់គ្រងនៃផលិតកម្មរបស់ខ្លួន ប៉ុន្តែដើម្បីឱ្យការគ្រប់គ្រងក្រុមហ៊ុនមានប្រសិទ្ធភាពខ្ពស់គឺ អាស្រ័យលើអ្នកគ្រប់គ្រងចេះអភិវឌ្ឍខ្លួន និងចេះប្រើយុទ្ធសាស្ត្រយ៉ាងណាដើម្បីគ្រប់គ្រងឱ្យកាន់តែមានភាពរីកចម្រើន។

ជាក់ស្ដែងក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់ ជាក្រុមហ៊ុនមួយដែលបានដំណើការមុខជំនួញទៅលើវិស័យកសិឧស្សាហកម្ម និងចំណីអាហារដោយផ្ដោតសំខាន់លើការប្រតិបត្តិអាជីវកម្មផលិតចំណីសត្វ (Feed) ការចិញ្ចឹមសត្វ (Farm) និងការផលិតចំណីអាហារ (Food) ជាច្រើនឆ្នាំមកហើយនៅក្នុងប្រទេសកម្ពុជា។ បន្ថែមពីនេះទៅទៀត ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់ ក៏ជាក្រុមហ៊ុនមួយដែលមានការគ្រប់គ្រងផលិតកម្មបានយ៉ាងល្អដោយគេផ្ដោតទៅលើការផលិតផលិតផលដែលមានគុណភាពខ្ពស់ និងស្របទៅតាមតម្រូវការពិតប្រាកដរបស់អ្នកប្រើប្រាស់ និងអ្នកបរិភោគផងដែរ។ ដោយហេតុក្រុមហ៊ុនមួយនេះនៅតែបន្តជាក្រុមហ៊ុនដែលឈរជើងនៅ

លើទីផ្សារផលិតកម្មរហូតមកដល់បច្ចុប្បន្នបានយ៉ាងល្អនេះហើយ ទើបក្រុមយើងខ្ញុំមានចំណាប់អារម្មណ៍ និងចង់សិក្សាស្រាវជ្រាវពីក្រុមហ៊ុនមួយនេះ ដើម្បីស្វែងយល់ឱ្យកាន់តែលម្អិតអំពីដំណើរការគ្រប់គ្រងនៅក្នុងក្រុមហ៊ុន ដោយក្រុមយើងខ្ញុំបានលើកយកប្រធានបទ "**ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់**" យកមកសិក្សាស្រាវជ្រាវ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយយើងបានដឹងហើយថា ក្រុមហ៊ុន ឬអង្គភាពមួយរីកចម្រើនបាន លុះត្រាតែមានការគ្រប់គ្រងដំណើរការល្អទើបអាចធ្វើប្រតិបត្តិការអាជីវកម្មទទួលបានជោគជ័យជាពិសេសគឺការគ្រប់គ្រងហិរញ្ញវត្ថុ និតិវិធីក្នុងការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន គឺជាកត្តាមួយសំខាន់ក្នុងការអនុវត្តការងារឱ្យស្របទៅតាមផែនការដែលបានគ្រោងទុក។ ហេតុដូចនេះហើយ ទើបក្រុមយើងខ្ញុំសម្រេចលើកយកនៅចំណុចមួយចំនួនដែលទាក់ទងទៅនឹងការរៀបចំគម្រោងថវិកាមកធ្វើការសិក្សាស្រាវជ្រាវក្នុងសារណាមួយនេះ ៖

១. តើក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់ មាននីតិវិធីអ្វីខ្លះក្នុងការរៀបចំគម្រោងថវិកានៅក្នុងអង្គភាព?

២. តើដំណើរការនៃការរៀបចំគម្រោងថវិកាបានផ្តល់នូវអត្ថប្រយោជន៍យ៉ាងដូចម្តេចដល់ក្រុមហ៊ុន?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនៃប្រធានបទខាងលើនេះ គឺដើម្បីយល់ដឹងអំពីសារៈសំខាន់នៃការរៀបចំគម្រោងថវិកាដែលត្រឹមត្រូវ និងផ្នែកមួយចំនួនដែលពាក់ព័ន្ធដើម្បីសម្រេចបាននូវគោលបំណងជាក់លាក់ដែលបានគ្រោងទុកដូចខាងក្រោម៖

- សិក្សាអំពីស្ថានភាពទូទៅរបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់
- ស្វែងយល់ពីទស្សនៈវិស័យ និងបេសកកម្មរបស់ក្រុមហ៊ុនផលិតកម្ម
- ស្វែងយល់ពីរចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រដឹកនាំរបស់ក្រុមហ៊ុន
- យល់ដឹងអំពីដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុនផលិតកម្ម
- សិក្សាអំពីគោលការណ៍ នីតិវិធីនៃការអនុវត្តគម្រោងថវិកាដែលបានគ្រោង
- វិភាគពីចំណុចខ្លាំង និងខ្សោយក្នុងការដោះស្រាយបញ្ហា
- គុណសម្បត្តិ និងគុណវិបត្តិនៃការរៀបចំគម្រោងថវិកា

## ១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ ដែនកំណត់

ការសិក្សាស្រាវជ្រាវនេះ គឺបានផ្តោតលើការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់។ ដើម្បីឱ្យប្រធានបទខាងលើមានខ្លឹមសារពេញលេញល្អក្នុងការបកស្រាយឱ្យស៊ីជម្រៅ និងងាយស្រួលថែមមួយកម្រិតទៀតនោះ យើងបានជ្រើរើសគោលដៅដើរទៅតាមពេលវេលាដែលកំណត់ទុកដោយគណៈគ្រប់គ្រងនៃសាកលវិទ្យាល័យវ៉ាន់ដា។ ក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវ និងកំណត់យកទីតាំងនៃក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់ ដែលមានទីតាំងសិត្ថនៅ ផ្លូវជាតិលេខ៤ ភូមិផ្សារកំបូល សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា។

### ១.៤.២ វិសាលភាព

អាស្រ័យដោយវិសាលភាពនៃការរៀបចំគម្រោងថវិកាមានលក្ខណៈទូលំទូលាយ ហើយពេលវេលាក៏

មានកំណត់ ហេតុដូច្នេះហើយ ក្រុមយើងខ្ញុំសូមលើកយកព័ត៌មានតែក្នុងអំឡុងឆ្នាំ ២០១៩ ប៉ុណ្ណោះដើម្បីលើកយកមកបកស្រាយក្នុងការសិក្សាស្រាវជ្រាវមួយនេះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវត្រូវបានប្រើវិធីសាស្ត្រគុណវិស័យ (Qualitative Methods) ដោយផ្តោតចម្បងលើការវិភាគទិន្នន័យបន្ទាប់បន្សំដែលបានមកពីប្រភពព័ត៌មានអេឡិចត្រូនិក និងឯកសារពាក់ព័ន្ធ។ ទិន្នន័យត្រូវបានប្រមូលសម្រាប់ការវិភាគដើម្បីយល់ដឹងអំពីការរៀបចំគម្រោងថវិកានៅក្នុងក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់ និងការអនុវត្តស្តង់ដារប្រតិបត្តិការសម្រាប់ដំណើរការគ្រប់គ្រងហិរញ្ញវត្ថុ។

### ១.៥.១ ការបកស្រាយសំណួរទី១

**សម្រាប់សំណួរស្រាវជ្រាវទី១៖** ត្រូវបានប្រមូលទិន្នន័យតាមរយៈការវិភាគឯកសារស្រាវជ្រាវ ទិន្នន័យ និងការសាកសួរពីនាយកផ្នែកហិរញ្ញវត្ថុក្នុងក្រុមហ៊ុនផលិតកម្ម លោកគ្រូ អ្នកគ្រូ និងរៀមច្បង ដើម្បីយកមកបកស្រាយអំពីដំណើរការរៀបចំផែនការថវិកា កត្តាដែលមានឥទ្ធិពល ការអនុវត្តវិធីសាស្ត្រ និងមានកត្តារួមផ្សំអ្វីខ្លះដែលត្រូវបានអនុវត្តទើបអាចឱ្យការគ្រប់គ្រងដំណើរការផលិតមានប្រសិទ្ធភាពខ្ពស់បំផុត។

### ១.៥.២ ការបកស្រាយសំណួរទី២

**សម្រាប់សំណួរស្រាវជ្រាវទី២៖** ត្រូវបានប្រមូលទិន្នន័យតាមរយៈការវិភាគលទ្ធផលនៃការធ្វើផែនការថវិកាដែលបានអនុវត្ត និងការស្នើសុំការសម្តែងនូវមតិយោបល់ពីអ្នកមានបទពិសោធន៍ក្នុងវិស័យហិរញ្ញវត្ថុ ដើម្បីបកស្រាយអំពីអត្ថប្រយោជន៍ដែលក្រុមហ៊ុនអាចទទួលបានពីការរៀបចំផែនការថវិកាដោយប្រើវិធីសាស្ត្រចម្រុះ និងបញ្ហាប្រឈមដែលអាចប្រទះក្នុងដំណើរការនេះ (ឧ. ការប្រមូលទិន្នន័យមិនគ្រប់គ្រាន់, ការវិវឌ្ឍនៃទីផ្សារ, និងថវិកាបម្រុងជាដើម)។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវចំពោះប្រធានបទខាងលើបានផ្តល់នូវសារៈសំខាន់យ៉ាងខ្លាំងក្នុងការជួយដល់ក្រុមអ្នកស្រាវជ្រាវ ស្ថាប័នផ្ទាល់ និងសង្គមជាតិទាំងមូលដូចខាងក្រោម៖

- **ចំពោះក្រុមអ្នកស្រាវជ្រាវ**
  - បង្កើនជំនាញក្នុងការវិភាគ និងរៀបចំផែនការថវិកា
  - ទទួលបានចំណេះដឹងអំពីដំណើរការគ្រប់គ្រងថវិកាដែលមានប្រសិទ្ធភាព
  - បង្កើនសមត្ថភាពធ្វើការងារជាក្រុម និងការចែករំលែកព័ត៌មាន
  - រៀនអំពីការទទួលខុសត្រូវក្នុងការស្រាវជ្រាវ និងជួយកែលម្អចំណុចខ្វះខាតគ្នាទៅវិញទៅមក
- **ចំពោះស្ថាប័ន**
  - អាចសម្គាល់ចំណុចខ្វះខាតក្នុងដំណើរការរៀបចំគម្រោងថវិកាដើម្បីកែលម្អនិងអភិវឌ្ឍន៍
  - ជួយបង្កើនការជឿទុកចិត្តពីអតិថិជន និងភាគីពាក់ពន្ធ័
  - ផ្តល់ចំណេះដឹងសម្រាប់ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រគ្រប់គ្រង
- **ចំពោះសង្គមជាតិ**
  - ផ្សព្វផ្សាយចំណេះដឹងទៅដល់និស្សិត និងស្ថាប័នអប់រំនានា
  - បង្កើតជាឯកសារយោងសម្រាប់និស្សិតជំនាន់ក្រោយក្នុងការប្រើប្រាស់តាមតម្រូវការ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវធ្វើឡើង ដើម្បីយល់កាន់តែច្បាស់នៅចំណុចនីមួយៗ និងបានធ្វើឡើងដោយធ្វើការរាប់បញ្ចូលចំណុចដែលមានក្នុងនោះ សេចក្តីផ្តើមនៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ សេចក្តីសន្និដ្ឋាន អនុសាសន៍និងមានចំណុចជាច្រើនទៀត ។ ក្រោយពីបានសិក្សាស្រាវជ្រាវមក ក្រុមយើងខ្ញុំក៏បានបែងចែកជា ៥ ជំពូកដែលរៀបរាប់ដូចខាងក្រោម៖

**ជំពូកទី ១ ៖ សេចក្តីផ្តើម** ការបរិយាយសង្ខេបពីលំនាំបញ្ហា គោលបំណង មូលហេតុនៃការស្រាវជ្រាវ ចំណោទបញ្ហា ដែនកំណត់និងវិសាលភាព ហេតុផលមួយចំនួនដែលបង្កើតឱ្យមានការស្រាវជ្រាវនេះឡើង។

**ជំពូកទី ២ ៖ រំលឹកទ្រឹស្តី** ការលើកឡើងពីទ្រឹស្តីដែលពាក់ព័ន្ធ និងវិធីសាស្ត្រនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុនផលិតកម្ម។

**ជំពូកទី ៣ ៖ លទ្ធផលនៃការស្រាវជ្រាវ** ការបង្ហាញពីស្ថានភាពទូទៅ គោលនយោបាយ និងរចនាសម្ព័ន្ធការងាររបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់។

**ជំពូកទី ៤ ៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ** ការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយដែលគួរកែលម្អរបស់ក្រុមហ៊ុន។

**ជំពូកទី ៥ ៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** សន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានលើកឡើងក្នុងអត្ថបទ និងផ្តល់ជាអនុសាសន៍ទៅលើចំណុចដែលមានកង្វះខាត ដើម្បីកែលម្អ។

នៅក្នុងជំពូកចុងក្រោយនេះយើងនឹងធ្វើការសំយោគឡើងវិញនូវរាល់លទ្ធផលដែលក្រុមយើងខ្ញុំបានស្រាវជ្រាវដើម្បីឆ្លើយតបទៅនឹង សំណួរស្រាវជ្រាវ គោលបំណងស្រាវជ្រាវ ដែលបានចងក្រងនៅក្នុងអត្ថបទសារណានេះ។ ម្យ៉ាងវិញទៀតក្រុមស្រាវជ្រាវយើងខ្ញុំបានរំលេចនូវអនុសាសន៍ដែលល្អៗមួយចំនួនទៀតដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវ ដើម្បីជាគំនិតក្នុងការពិចារណាក្នុងន័យកែលម្អទៅកាន់ជ្រុងណាមួយដើម្បីបង្កើនការអភិវឌ្ឍន៍ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព។

# ជំពូកទី ២
# ដំណើរការនៃការរៀបចំគម្រោងថវិកា

## ២.១ លក្ខណៈទូទៅនៃការរៀបចំគម្រោងថវិកា

### ២.១.១ និយមន័យការរៀបចំគម្រោងថវិកា

**គម្រោងថវិកា (Budget Plan)** ជាសេចក្ដីសង្ខេបនៃចំណូលប៉ាន់ស្មាន និងការបែងចែកថវិកា ដើម្បីប្រើប្រាស់ក្នុងអាជីវកម្ម ឬអង្គភាពណាមួយក្នុងអំឡុងពេលជាក់លាក់។ វាជាការព្យាករណ៍នូវការហូរចូល និងហូរចេញនូវសាច់ប្រាក់ដែលបានពីចំណូល ឬចំណាយទៅលើប្រតិបត្តិការនានារបស់ក្រុមហ៊ុន ដើម្បីធានានូវការចំណាយសមរម្យ និងសម្រេចបាននូវគោលដៅហិរញ្ញវត្ថុ[1]។

**ការរៀបចំគម្រោង (Project Planning)** គឺជាការរៀបចំចាត់ចែង ការដឹកនាំអនុវត្ត និងការត្រួតពិនិត្យមើលទៅលើ ធនធាន ពេលវេលា គោលបំណងឱ្យបានជាក់លាក់ដើម្បីសម្រេចទិសដៅ និងទស្សនៈវិស័យបេសកកម្មរបស់ សហគ្រាស ស្ថាប័ន ឬអង្គភាព[2]។

**ក្រុមហ៊ុនផលិតកម្ម (Manufacturing Company)** គឺសំដៅដល់ក្រុមហ៊ុន ដែលបានទិញវត្ថុធាតុដើមមកធ្វើដំណើរការនៃការផលិតដែលបម្លែងវត្ថុធាតុដើមទៅជាផលិតផលសម្រេច។ ផលិតផលទាំងនេះអាចត្រូវបានចែកចាយដោយផ្ទាល់ទៅកាន់អតិថិជន ឬតាមរយៈអ្នកចែកចាយផ្សេងៗទៀតដើម្បីឆ្ពោះទៅដល់ការលក់។ មានក្រុមហ៊ុនផលិតខ្លះដែលផលិតជាតុផ្សំ ដែលត្រូវបានបញ្ចូលទៅក្នុងផលិតផលនៃក្រុមហ៊ុនផ្សេងៗ[3]។

ការរៀបចំគម្រោងថវិកា ត្រូវបានពិពណ៌នាដោយផែនការជាច្រើន មកពីផែនការយុទ្ធសាស្ត្រសរុបរបស់គម្រោង ទៅកផែនការអនុវត្តដែលមានលម្អិត។ ការរៀបចំថវិកា គឺជាដំណើរការប៉ាន់ប្រមាណតម្រូវការហិរញ្ញវត្ថុរបស់ផែនការទាំងនេះ ការប្រាប់ប្រកពថវិកា និងការទទួលយកវិធានការណ៍ដើម្បីធានាថាថវិកានោះត្រូវបានផ្ដល់ជូនទៅតាមពេលវេលាត្រឹមត្រូវ។ បច្ចុប្បន្នរដ្ឋាភិបាលបានអនុវត្ត ការរៀបចំថវិកាកម្មវិធីក្នុងក្រសួង និងស្ថាប័នរដ្ឋជាច្រើន ហើយថវិកាសម្រាប់គម្រោង ឥឡូវនេះត្រូវបានរួមបញ្ចូលជាផ្នែកមួយនៃថវិកាកម្មវិធីដែលពាក់ព័ន្ធ។ គម្រោងថវិកាអាចត្រូវបានប៉ាន់ប្រមាណសម្រាប់រយៈពេលនានាដែលខុសគ្នា។ ជាទូទៅ ការរៀបចំគម្រោងថវិកាកាន់តែលម្អិតគឺកាន់តែប្រសើរ។ រយៈពេលដែលប្រើប្រាស់ថវិកាប្រកបដោយការពេញនិយមបំផុតមានដូចខាងក្រោម៖

- **គម្រោងថវិកាជាកញ្ចប់** : ពេលដែលគម្រោងត្រូវបានអនុម័ត វានឹងត្រូវបានដាក់ចេញជាថវិកាសម្រាប់កម្មវិធីទាំងមូល។ កម្មវិធីនេះភាគច្រើន ត្រូវបានបំបែកជាការប៉ាន់ប្រមាណប្រភេទចំណាយទូលំទូលាយ ហើយក្នុងដំណាក់កាលនេះត្រូវបានពិចារណាពីដំណាក់កាលសំខាន់ៗដើម្បីធានាថាការចំណាយប្រចាំឆ្នាំនឹងត្រូវបានគ្រប់គ្រងស្របតាមផែនការនៃការអនុវត្ត។
- **គម្រោងថវិការយៈពេលបីឆ្នាំ** : បីឆ្នាំគឺជារយៈពេលជ្រើសរើសដោយរដ្ឋាភិបាលសម្រាប់ផែនការថវិការយៈពេលមធ្យមរបស់ខ្លួន។ ជាផ្នែកមួយនៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ រដ្ឋាភិបាល

[1] iauoffsa. (2024, April 22). *ការរៀបចំផែនការថវិកា.* Retrieved from https://iauoffsa.gov.kh/wp-content/uploads/2024/04/22.pdf

[2] startupcambodia. (2021, December 07). *តើវដ្ដជីវិតរបស់គម្រោងជាអ្វី?* Retrieved from https://startupcambodia.gov.kh/resource/category/blog/246

[3] netsuite. (2022, June 16). *What Is Manufacturing?* Retrieved from https://www.netsuite.com/portal/resource/articles/inventory-management/manufacturing.shtml

រៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) រយៈពេលបីឆ្នាំ ដែលត្រូវបានណែនាំដោយក្របខ័ណ្ឌសារពើពន្ធរយៈពេលមធ្យម (MTFF) ។

- **គម្រោងថវិកាប្រចាំឆ្នាំ** : រយៈពេលស្តង់ដារសម្រាប់ការបែងចែកថវិកាដល់ទីភ្នាក់ងារ និងអ្នកគ្រប់គ្រងគម្រោងនានា គឺមួយឆ្នាំ។ រដ្ឋាភិបាលអនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន (Le the Annual Budget) សម្រាប់រយៈពេលពីខែមករាដល់ខែធ្នូជារៀងរាល់ឆ្នាំ ហើយវាក៏ជាគម្រោងថវិកាដែលពេញនិយមបំផុតសម្រាប់សហគ្រាស ស្ថាប័ន ឬអង្គភាពនានា មិនថាខ្នាតតូច មធ្យម និងខ្នាតធំនោះទេ។
- **គម្រោងថវិកាប្រចាំត្រីមាស/ ប្រចាំខែ** : តម្រូវការមូលនិធិសម្រាប់គម្រោងនីមួយៗ ទំនងជាមិនស្មើគ្នាក្នុងរយៈពេលមួយឆ្នាំទាំងអស់នោះទេ។ ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការព្យាករណ៍តម្រូវការមូលនិធិជាមុនយ៉ាងហោចណាស់ប្រចាំត្រីមាស និងជាប្រចាំខែ។
- **គម្រោងសម្រាប់ថវិកាកិច្ចការជាក់លាក់ ឬសកម្មភាព** : ការប៉ាន់ប្រមាណសម្រាប់សកម្មភាពនីមួយៗដែលអនុវត្តដោយគម្រោងនឹងត្រូវបានបង្កើតឡើងដោយកិច្ចការជាច្រើន។ ប្រព័ន្ធថវិកាដ៏ល្អនឹងប៉ាន់ប្រមាណការចំណាយនៃកិច្ចការ និងសកម្មភាពទាំងនេះ ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៃថវិកាសាច់ប្រាក់ និងការប៉ាន់ប្រមាណប្រចាំឆ្នាំ[4]។

### ២.១.២ ប្រវត្តិនៃការរៀបចំគម្រោងថវិកា

ការអភិវឌ្ឍនៃការរៀបចំថវិកា គឺជាគំនិតដែលទទួលស្គាល់នៅសម័យថ្មី ប៉ុន្តែគ្រាប់ពូជរបស់វាបានដាំដុះតាំងពីបុរាណកាល។ ថវិកាចាប់ផ្តើមជាទម្រង់ផែនការចំណូលសម្រាប់អង្គភាពរដ្ឋាភិបាល។ វាបានក្លាយជាការអនុវត្តធម្មតាក្នុងរដ្ឋបាលរដ្ឋអាមេរិកនៅចន្លោះឆ្នាំ ១៨៨០ ដល់ ១៩២១។ ចំណែកឯទីក្រុងគឺជាអង្គភាពដំបូងបំផុតដែលបានអនុវត្តប្រព័ន្ធថវិកា បន្ទាប់មកប្រទេសបន្តធ្វើតាម និងចុងក្រោយសហព័ន្ធរដ្ឋាភិបាលបានអនុវត្តផងដែរ។ ក្នុងទសវត្សទី១ និងទី២ នៃសតវត្សទី២០ (១៩០០-១៩២០) គឺជាឈានដំបូងនៃការអភិវឌ្ឍថវិកាអាជីវកម្ម។ វាបានលូតលាស់ដោយសារសេចក្តីពិចារណារបស់វិស្វករឧស្សាហកម្ម និងគណនេយ្យថ្លៃដើម។

ប៉ុន្តែថវិកាអាជីវកម្មបានចាប់ផុសផុយយ៉ាងពេញលេញនៅ ទសវត្សទី៣ (១៩៣០-១៩៣៩)។ ក្រោយពីនេះ ទស្សនៈអំពីថវិកាបានផ្លាស់ប្តូរពីការផ្តល់ប្រាក់ដើម្បីគ្រប់គ្រងការចំណាយ ទៅជាការកាត់បន្ថយការចំណាយឱ្យអតិផរណា។ អំឡុងសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥) ការរៀបចំថវិកាបានអភិវឌ្ឍបន្ថែមទៀត ដោយសារស្ថានភាពខ្វះខាតសម្ភារៈ និងកាលវិភាគដឹកជញ្ជូនមានសារៈសំខាន់មិនតិចជាងការគ្រប់គ្រងថ្លៃដើម។

នៅពេលក្រោយមក Behavioral Scientists (អ្នកវិទ្យាសាស្ត្រផ្លូវអប់រំ និងចិត្តវិទ្យា) ក៏បានចូលរួមក្នុងការអភិវឌ្ឍថវិកាផងដែរ។ បន្ថែមពីនេះ អ្នកគណនេយ្យសាស្ត្រ (statisticians) និងសេដ្ឋកិច្ចវិទូ (economists) ក៏បានជួយអភិវឌ្ឍការរៀបចំថវិកាតាមរយៈការស្រាវជ្រាវអំពីចង្វាក់អាជីវកម្ម[5][5]។

[5]

[4] elearning-sop. (2019, December 02). *Planning and Budgeting. Budget Timescales*. Retrieved from https://elearning-sop.mef.gov.kh/courses/financial-management/lessons/4-planning-and-budgeting

[5] Flesher, Dale L. and Flesher, Tonya K. (1979). *Short History Of Budgeting, Woman C.P.A.* Retrieved from https://egrove.olemiss.edu/cgi/viewcontent.cgi?article=2861&context=wcpa

នៅក្នុងប្រទេសកម្ពុជា ចាប់ផ្តើមមានការចាប់អារម្មណ៍លើប្រវត្តិនៃការរៀបចំគម្រោងថវិកាក្នុងអំឡុងប៉ុន្មានឆ្នាំថ្មីៗនេះ។ អត្ថបទ និងសៀវភៅជាបន្តបន្ទាប់គឺជាភស្តុតាងនៃការចាប់អារម្មណ៍កាន់តែខ្លាំងឡើងនៅក្នុងអតីតកាលនៃការធ្វើគម្រោងថវិកា។

ជាក់ស្តែងចាប់តាំងពីឆ្នាំ ២០០៦ មកគម្រោងថវិកាជាតិកម្ពុជា បានវិភាគថវិកាជាតិ និងការមានព័ត៌មានថវិកាជាសាធារណៈនៅក្នុងដំណើរការថវិកាជាតិទាំងមូល។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា គឺជាអង្គការសមាជិកភាពសម្រាប់ អង្គការជាតិ និងអង្គការអន្តរជាតិធ្វើការនៅក្នុងប្រទេសកម្ពុជា ដែលបានចាប់ផ្តើមការងារតាមដានថវិកាជាតិ ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គម្រោងថវិកាជាតិបានធ្វើការតស៊ូមតិយ៉ាងម៉ឺងម៉ាត់ ដើម្បីជម្រុញឱ្យកាន់តែមានតម្លាភាពបន្ថែមទៀតក្នុងដំណើរការថវិកា ហើយឱ្យមានភាពស៊ីគ្នាកាន់តែប្រសើរឡើងរវាងថវិកាជាតិកម្ពុជា ជាមួយនឹងគម្រោងអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ[6]។

**២.១.៣ ទ្រឹស្តីនៃការធ្វើគម្រោងថវិកា**

គម្រោងមិនមែនជាផ្នែកតែមួយនៃចំណេះដឹងដែលបង្រួបបង្រួមនោះទេ ប៉ុន្តែជាវិស័យចម្រុះ និងវិវឌ្ឍនភាពដែលឆ្លុះបញ្ចាំងពីទស្សនវិស័យ គំរូ និងទំនៀមទម្លាប់ផ្សេងៗគ្នា។

គម្រោងថវិកា គឺជាការប្រមូលផ្តុំនៃសកម្មភាពជាច្រើនដែលពាក់ព័ន្ធគ្នាដែលនឹងត្រូវអនុវត្តតាមបែបដែលបានរៀបចំរួចជាស្រេចដោយមានចំណុចចាប់ផ្តើមនិងបញ្ចប់ច្បាស់លាស់។ គោលបំណងរបស់គម្រោងគឺធ្វើយ៉ាងណាឱ្យសម្រេចបាននូវលទ្ធផលជាក់លាក់ដើម្បីបំពេញតាមតម្រូវការយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនមួយ។ សកម្មភាពនានារបស់គម្រោងមានទំនាក់ទំនងជាលំដាប់លំដោយពោលគឺសកម្មភាពជាក់ស្តែងមួយចំនួនត្រូវតែធ្វើឱ្យរួចរាល់មុននឹងសកម្មភាពថ្មីមួយទៀតអាចចាប់ផ្តើមបានដោយផ្អែកលើលក្ខណៈបច្ចេកទេស។

ទ្រឹស្តីនៃការធ្វើគម្រោងថវិកាមានសារៈសំខាន់ ព្រោះវាអាចជួយអ្នករៀបចំផែនការឱ្យយល់អំពីស្ថានភាពស្មុគស្មាញ ហានិភ័យដែលពួកគេត្រូវប្រឈមមុខ និងណែនាំការសម្រេចចិត្ត និងសកម្មភាពរបស់ពួកគេ។ ការធ្វើគម្រោងក៏អាចជួយអ្នករៀបចំគម្រោងគិតយ៉ាងត្រិះរិះពិចារណាលើការសន្មត់ តម្លៃ និងភាពលំអៀងរបស់ពួកគេ និងរបៀបដែលពួកគេ ប៉ះពាល់ដល់ការងាររបស់ពួកគេ។ ជាងនេះទៅទៀត ទ្រឹស្តីនៃការធ្វើគម្រោងអាចជួយអ្នករៀបចំគម្រោងទំនាក់ទំនង និងបង្ហាញអំពីភាពត្រឹមត្រូវនៃគំនិត និងសំណើរបស់ពួកគេ ហើយចូលរួមជាមួយភាគីពាក់ព័ន្ធ និងវិន័យផ្សេងទៀត។

ការពិភាក្សាទ្រឹស្តីគម្រោងណែនាំជាប្រធានបទមួយដែលពិបាក តែចាំបាច់ព្រោះថាវាអាចផ្តល់លទ្ធភាពឱ្យពួកគេអាចទទួលបានវិសាលភាពនៃការសម្រេចចិត្ត។ គោលគំនិតនៃការបង្កើតគម្រោងនេះ គឺសំដៅលើផ្នែក ontological, epistemological និងគោលការណ៍នៃការសម្រេចចិត្តដើម្បីគោលដៅ និងធ្វើគម្រោង[7]។

## ២.២ វិធីសាស្ត្រក្នុងការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុនផលិតកម្ម

ក្នុងក្រុមហ៊ុនផលិតកម្មមួយៗ ការរៀបចំផែនការថវិកាមានសារៈសំខាន់ក្នុ ងការជម្រុញការគ្រប់គ្រងហិរញ្ញវត្ថុ និងធានាការប្រកួតប្រជែងក្នុងទីផ្សារ។

[6] opendevelopmentcambodia. (2015, December 08). *Budget*. Retrieved from https://opendevelopmentcambodia.net/topics/budget/
[7] អ្នកនិពន្ធ ម៉ន ពេជ្រខេមរា. បោះពុម្ពឆ្នាំ ២០១០. *សៀវភៅគ្រប់គ្រងគម្រោង*. ទំព័រទី៣. ភ្នំពេញ។

ផែនការថវិកាជាការគ្រោងទុកអំពីប្រាក់ចំណូល និងការចំណាយក្នុងអាជីវកម្ម ដែលអាចជួយក្រុមហ៊ុនក្នុងការបែងចែកធនធានយ៉ាងមានប្រសិទ្ធភាព និងបន្ថែមលើភាពមានចំណេញ។ លើសពីនេះ ការរៀបចំផែនការថវិកាផងដែរ អាចជួយក្រុមហ៊ុនក្នុងការរៀបចំយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីសម្រេចបាននូវគោលដៅដែលបានកំណត់។ ហើយជាទូទៅដំណើរការក្នុងការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុនផលិតកម្មនេះត្រូវបានអនុវត្តតាមជំហានខាងក្រោម៖

**១. ការវិភាគស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្ន**

ដំបូងក្រុមហ៊ុនត្រូវពិនិត្យមើលស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្ន ដើម្បីស្វែងយល់អំពីប្រាក់ចំណូល ការចំណាយ ការខាតបង់ និងការវិនិយោគ។ ការវិភាគនេះអាចផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុនិងទិន្នន័យសំខាន់ផ្សេងៗ។

**២. ការកំណត់គោលដៅហិរញ្ញវត្ថុ**

ក្រុមហ៊ុនត្រូវកំណត់គោលដៅផ្នែកហិរញ្ញវត្ថុសម្រាប់អនុវត្តនៅក្នុងរយៈពេលបណ្តាញ (១ឆ្នាំ ឬច្រើនឆ្នាំ) ដូចជា ការកើនឡើងនៃប្រាក់ចំណូល ការបង្កើនប្រាក់ចំណេញ និងការប្រមូលប្រាក់បានល្អ។

**៣. ការវាយតម្លៃការចំណាយ និងចំណូល**

ដើម្បីបង្កើតផែនការថវិកាបានត្រឹមត្រូវ ក្រុមហ៊ុនត្រូវវាយតម្លៃចំណូលដែលអាចទទួលបាន និងការចំណាយសម្រាប់កិច្ចការផ្សេងៗ រួមមានការចំណាយលើវត្ថុធាតុដើម កម្លាំងពលកម្ម និងការប្រតិបត្តិ។

**៤. ការត្រួតពិនិត្យ និងកែតម្រូវផែនការថវិកា**

ក្រោយពីអនុវត្តផែនការថវិកា ក្រុមហ៊ុនត្រូវត្រួតពិនិត្យ និងបែងចែកស្ថានភាពជាក់ស្តែងជាមួយផែនការដែលបានកំណត់។ ប្រសិនបើមានបញ្ហា ឬការរំខាន ក្រុមហ៊ុនត្រូវធ្វើការកែតម្រូវឱ្យបានទាន់ពេលវេលា និងសមស្របទៅតាមស្ថានភាពជាក់ស្តែងដែលកំពុងជួប។

**៥. ការធ្វើបទបង្ហាញ និងអនុម័ត**

នៅចុងបញ្ចប់ ក្រុមហ៊ុនត្រូវធ្វើបទបង្ហាញស្តីពីផែនការថវិកានេះដល់អ្នកគ្រប់គ្រង និងអ្នកធ្វើការសម្រេចចិត្ត។ ការប្រើប្រាស់ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុអាចជួយឱ្យការអនុវត្តមានប្រសិទ្ធភាព។

**៦. ការបែងចែកថវិកាក្នុងផ្នែកផ្សេងៗ**

ក្រុមហ៊ុនត្រូវចែកថវិកាទៅតាមផ្នែកផ្សេងៗ ដូចជា ផ្នែកផលិតកម្ម ផ្នែកទីផ្សារ ផ្នែកលក់ និងផ្នែកអភិវឌ្ឍន៍។ ការបែងចែកនេះត្រូវអនុវត្តយ៉ាងប្រុងប្រយ័ត្ន ដើម្បីបំពេញតាមតម្រូវការរបស់ក្រុមហ៊ុន[8]។

ដោយសង្ខេប ការរៀបចំផែនការថវិកាក្នុងក្រុមហ៊ុនផលិតកម្មត្រូវមានការយល់ដឹងជាក់លាក់ពីស្ថានភាពហិរញ្ញវត្ថុ ការគ្រប់គ្រងចំណូល និងចំណាយ ការបែងចែកថវិកាឱ្យសមស្រប និងការត្រួតពិនិត្យជាប្រចាំ។ នេះជាកូនសោសំខាន់ក្នុងការជម្រុញការរីកចម្រើននៃអាជីវកម្ម។

## ២.៣ អត្ថប្រយោជន៍នៃការរៀបចំគម្រោងថវិកា

ការរៀបចំគម្រោងថវិកា គឺជាកត្តាចម្បងមួយសំខាន់សម្រាប់ក្រុមហ៊ុនផលិតកម្ម។ វាជួយសម្រួលដល់ការគ្រប់គ្រងប្រភពថវិកា និងធានាថាអ្នកគ្រប់គ្រងអាចធ្វើការសម្រេចចិត្តបានត្រឹមត្រូវទាក់ទងនឹងការចំណាយ

[8] claconnect. (2025, March 24). *Strategic Budgeting, Forecasting in Manufacturing: Explore Key Strategies*. Retrieved from *https://www.claconnect.com/en/resources/blogs/manufacturing/strategic-budgeting-forecasting-in-manufacturing-explore-key-strategies?*

និងការវិនិយោគ។ ការរៀបចំថវិកាជាផ្នែកមួយនៃការគ្រប់គ្រងការប្រកបអាជីវកម្ម ដើម្បីធានាថាក្រុមហ៊ុននឹងអាចបង្កើតផលិតផលបានតាមពេលវេលា និងការផ្តល់ជូននូវគុណភាពក្នុងការផ្គត់ផ្គង់សម្ភារៈដោយមិនផ្តាច់ពីការរក្សាគុណភាព និងការចំណាយសមស្រប។ គម្រោងថវិកានៅក្នុងក្រុមហ៊ុនផលិតកម្ម អាចជួយកាត់បន្ថយការចំណាយដែលមិនសំខាន់ និងការពិសោធន៍ អត្រាជួសជុល ដោយការកំណត់ថវិកាជាក់លាក់សម្រាប់ការផលិតផលិតផលនីមួយៗ។ បន្ថែមពីលើនេះ វាក៏អាចជួយក្រុមហ៊ុនមានថវិកាគ្រប់គ្រាន់ក្នុងការរចនាផលិតផលថ្មី និងកំណត់ប្រភពថវិកាផ្គត់ផ្គង់សម្ភារៈនានា ដើម្បីជួយបង្កើនប្រសិទ្ធភាពនៃដំណើរការផលិត។ ដូច្នេះការរៀបចំគម្រោងថវិកាជួយធានាថាក្រុមហ៊ុនផលិតកម្មអាចបន្តប្រកបអាជីវកម្មយ៉ាងប្រសើរបាន និងមានប្រសិទ្ធភាពក្នុងការប្រកួតប្រជែងនៅទីផ្សារ។

**២.៣.១ អត្ថប្រយោជន៍នៃការរៀបចំគម្រោងថវិកាចំពោះក្រុមហ៊ុន**

- **ការគ្រប់គ្រងធនធានយ៉ាងមានប្រសិទ្ធភាព**

នៅក្នុងក្រុមហ៊ុនផលិត ការរៀបចំថវិកាជួយឱ្យគ្រប់គ្រងធនធានប្រាក់បានយ៉ាងត្រឹមត្រូវ។ វាអនុញ្ញាតឱ្យអ្នកអាចគ្រប់គ្រងកម្ចី និងប្រាក់ចំណូលជាមួយការចំណាយក្នុងការផលិត។ ការរៀបចំថវិកាអាចជួយក្រុមហ៊ុនមើលឃើញថាតើពួកគេចំណាយនៅលើអ្វីខ្លះ ហើយអាចកំណត់អត្តសញ្ញាណប្រយោជន៍ក្នុងការប្រកួតប្រជែងជាមួយក្រុមហ៊ុនផ្សេងទៀត។

- **ងាយស្រួលក្នុងការផ្លាស់ប្តូរប្រកបដោយគោលបំណង**

ការរៀបចំថវិកាពួកគេច្រើនត្រូវការកំណត់គោលបំណងដូចជាការផលិត ការដឹកជញ្ជូន និងការលក់។ វាជួយក្រុមហ៊ុនក្នុងការត្រួតពិនិត្យ កាត់បន្ថយការចំណាយពេលវេលា និងធនធាន ដូច្នេះពួកគេអាចសម្រេចបានគោលបំណងក្នុងសម័យកំណត់បាន។

- **ការសម្រេចចិត្តដ៏ឆ្លាតវៃ**

ការរៀបចំថវិកាអាចផ្តល់ឱ្យអ្នកគ្រប់គ្រងនូវទិន្នន័យបង្ហាញពីការចំណាយ និងការចូលប្រាក់ដើម្បីជួយពួកគេក្នុងការសម្រេចចិត្តល្អៗនៅក្នុងការអនុវត្តន៍យុទ្ធសាស្រ្ត។ ការបង្ហាញពីការងារមានប្រសិទ្ធភាពកំណត់ឱ្យមានសំណុំបែបបទដែលមានជួយបង្កើនទ្រព្យសកម្មសម្រាប់ក្រុមហ៊ុន។

- **ជំនួយដល់ការត្រួតពិនិត្យ និងការព្យាករណ៍**

ពេលដែលក្រុមហ៊ុនផលិតមានការរៀបចំថវិកាឱ្យបានត្រឹមត្រូវ វាងាយស្រួលសម្រាប់ពួកគេក្នុងការត្រួតពិនិត្យការចំណាយ និងការប្រាក់របស់ពួកគេ។ ការត្រួតពិនិត្យនេះអាចកំណត់ស្ថានភាពការប្រតិបត្តិការបានយ៉ាងត្រឹមត្រូវ ព្រមទាំងអាចធ្វើការព្យាករណ៍អំពីការសម្រេចចិត្តអនាគតដោយប្រើប្រាស់ទិន្នន័យជាក់ស្តែង។

- **ការកែលម្អ និងជាជំនួយក្នុងទីផ្សារប្រកួតប្រជែង**

ក្រុមហ៊ុនផលិតដែលអនុវត្តន៍ការរៀបចំថវិកាដែលបានវាយតម្លៃយ៉ាងត្រឹមត្រូវ នឹងអាចប្រកួតប្រជែងក្នុងទីផ្សារបាន។ ពួកគេអាចប្រើប្រាស់ចំណាយទាំងស្រុងយ៉ាងមានប្រសិទ្ធភាព និងធ្វើការសិក្សាបន្ថែមអំពីការគ្រប់គ្រង និងបច្ចេកវិទ្យាថ្មីៗដើម្បីបង្កើតផលិតផលឱ្យបានល្អប្រសើរឡើង។

**២.៣.២ អត្ថប្រយោជន៍នៃការរៀបចំគម្រោងថវិកាចំពោះមជ្ឈដ្ឋានខាងក្រៅ**

- **អ្នកផ្គត់ផ្គង់ និងដៃគូអាជីវកម្ម៖** មានភាពច្បាស់លាស់អំពីបរិមាណ និងពេលវេលាបញ្ជាទិញ បង្កើនការធ្វើការរួមគ្នាបានប្រសើរ។

- **អតិថិជន៖** ទទួលបានផលិតផលឬសេវាកម្មគ្រប់គ្រាន់ ទាន់ពេល បង្កើនទំនុកចិត្ត។
- **អ្នកវិនិយោគ និងស្ថាប័នហិរញ្ញវត្ថុ៖** ឃើញថាអង្គភាពមានការគ្រប់គ្រងល្អ ជួយទាក់ទាញវិនិយោគឬទទួលបានឥណទានងាយស្រួល។
- **សហគមន៍៖** អង្គភាពអាចចំណាយលើសកម្មភាពសង្គម និងអភិវឌ្ឍន៍ដូចជា ការចូលរួមក្នុងការអភិវឌ្ឍន៍សាលារៀន សុខាភិបាល និងបរិស្ថាន។
- **រដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ៖** ការរៀបចំថវិកាត្រឹមត្រូវជួយអោយអង្គភាពគោរពច្បាប់អាជីវកម្ម និងអាចបង់ពន្ធបានត្រឹមត្រូវ។

**២.៣.៣ ការវិភាគផលប៉ះពាល់នៃការរៀបចំគម្រោងថវិកា**

គេអាចមានប្រាក់បម្រុងគ្រប់គ្រាន់ដើម្បីទប់ស្កាត់បញ្ហាដែលអាចកើតឡើងក្នុងការបង្កើតផលិតផលថ្មី ឬហានិភ័យអាជីវម្មផ្សេងៗដែលអាចកើតមានឡើងដោយថាហេតុនៅក្នុងពេលអនាគត[៩]។ តែការរៀបចំគម្រោងថវិកាមួយបានជោគជ័យ គេក៏ត្រូវឆ្លងកាត់នូវបញ្ហា និងកំហិតក្នុងការរៀបចំគម្រោងមានការទាក់ទងទៅនឹង៖

- **ថវិកាដែលមានក្នុងធនធាន ៖** ចំនួនទឹកប្រាក់ដែលអង្គភាពមាននៅក្នុងដៃត្រូវតែប្រើប្រាស់ដោយប្រុងប្រយ័ត្ន និងសម្រាប់ករណីចាំបាច់។
- **ចំណូលដែលបានកំណត់ ៖** ផលចំណូលដែលអង្គភាពបានរកស៊ី ឬការព្យាករណ៍អំពីចំណូលនាពេលអនាគត។
- **ចំណាយដែលកំណត់នូវលទ្ធភាពធនធាន ៖** ចំណាយដែលអាចនាំផលប្រយោជន៍មកអង្គភាពត្រូវបានអនុញ្ញាត ខណៈពេលដែលការចំណាយទៅលើអ្វីដែលមិនចាំបាច់ ត្រូវបានកាត់បន្ថយឬលុបចោល។
- **ការគ្រប់គ្រងពេលវេលា ៖** ការប្រើពេលវេលាឱ្យមានប្រសិទ្ធភាព ត្រូវតែអាស្រ័យលើការរៀបចំផែនការប្រកបដោយសមត្ថភាព។
- **គុណភាពនៃសមិទ្ធផល ៖** គម្រោងណាមួយត្រូវមានគុណភាពល្អ ដើម្បីជៀសវាងបញ្ហាដែលអាចប៉ះពាល់ដល់អង្គភាព។

ការរៀបចំគម្រោងក្នុងក្រុមហ៊ុនផលិតមិនត្រឹមតែជាឧបករណ៍សម្រាប់កំណត់ចំណាយទេ។ វាជាកត្តាសំខាន់សម្រាប់ការធ្វើការត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុ និងកំណត់គោលបំណងដើម្បីធានាថាអ្នកគ្រប់គ្រងមានគំនិតច្បាស់លាស់ និងអាចចាត់តាំងសកម្មភាពការងារឱ្យសមរម្យ។ តែដោយសារស្ថានភាពទីផ្សារកំពុងផ្លាស់ប្តូរដោយល្បឿនលឿន អង្គភាពត្រូវតែបន្តអភិវឌ្ឍ និងកែប្រែយុទ្ធសាស្ត្រនានា ដើម្បីឆ្លើយតបទៅនឹងបាតុភូតថ្មីៗ។ ដូច្នេះ ការរៀបចំផែនការជាមុន និងការសហការជាប្រព័ន្ធ គឺជាគន្លឹះដ៏សំខាន់ដើម្បីឆ្ពោះទៅរកភាពជោគជ័យ។

[9] accounovation. (2024, June 25). *The Importance of Budgeting for Maximizing Profitability in Manufacturing*. Retrieved from https://accounovation.com/blogs/the-importance-of-budgeting-for-maximizing-profitability-in-manufacturing

# ជំពូកទី ៣
# ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់

## ៣.១ ស្ថានភាពទូទៅនៃក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់

### ៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា

មានមនុស្សជាច្រើនប្រហែលជាបានស្គាល់ក្រុមហ៊ុន Charoen Pokphand Group ដែលត្រូវបានគេដឹងថាជាក្រុមហ៊ុនកំពូលមួយនៅក្នុងប្រទេសថៃ និងមានការវិនិយោគនៅបណ្តាប្រទេសជាច្រើនជុំវិញតំបន់អាស៊ី រួមទាំងប្រទេសកម្ពុជាផងដែរ។ តាមរយៈការស្រាវជ្រាវលើសារព័ត៌មានអន្តរជាតិធំៗជាច្រើនបានឱ្យដឹងថា ក្រុមហ៊ុន Charoen Pokphand Group ត្រូវបានចាប់ផ្តើមឡើងដោយ ឪពុករបស់លោក Dhanin Chearavanont គឺលោក Chia Ek Chor ជាជនជាតិថៃ ដែលធ្លាប់រស់នៅប្រទេសចិន តែក្រោយពីត្រឡប់ពីប្រទេសចិនមកកាន់ប្រទេសថៃវិញ លោកបានបង្កើតហាងលក់គ្រាប់ធញ្ញជាតិមួយនាំចូលពីប្រទេសចិនសម្រាប់កសិករថៃនៅឆ្នាំ ១៩២១។

ក្រោយមកនៅឆ្នាំ ១៩៤៦ ក្រុមហ៊ុននេះបានប្តូរឈ្មោះមកជា Charoen Pokphand ដែលឈ្មោះនេះ មានអត្ថន័យថា វិបុលភាពសម្រាប់អ្នកប្រើប្រាស់។ នៅ ២ទស្សវត្សរ៍ ក្រោយមកក្រុមហ៊ុន CP បានងាកចេញពីការរកស៊ីផ្គត់ផ្គង់គ្រាប់ធញ្ញជាតិ មករកស៊ីលើការចិញ្ចឹមសត្វ និងពាណិជ្ជកម្មវិញម្តង ដោយក្រុមហ៊ុនបានពង្រីករោងចក្រចំណីសត្វរបស់ខ្លួនជាបន្តបន្ទាប់ នៅហុងកុង តៃវ៉ាន់ និងម៉ាឡេស៊ី។ ប៉ុន្តែនៅពីក្រោយការរីកចម្រើននេះ គឺត្រូវបានគេដឹងថា ដោយសារតែមានបុគ្គលដែលមានឥទ្ធិពលមួយរូបដែលដឹកនាំក្រុមហ៊ុននេះ បានយ៉ាងល្អបំផុតក្នុងចំណោមបងប្អូនប្រុសទាំង ៤នាក់ លោក Dhanin Chearavanont គឺជាកូនពៅគេ តែមានទេពកោសល្យខ្ពស់ជាងគេក្នុងការរកស៊ី។ នៅត្រឹមអាយុទើបតែ ៣០ឆ្នាំប៉ុណ្ណោះ លោកត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន CP Group ។





**រូបភាពរបស់លោក Dhanin Chearavanont និងបងប្រុសទាំងបី**

បច្ចុប្បន្ន ក្រុមហ៊ុន CP Group មិនត្រឹមតែរកស៊ីក្នុងវិស័យកសិឧស្សាហកម្មនោះទេ តែក៏មានការពង្រីកខ្លួនរកស៊ីជាបន្តបន្ទាប់រហូតដល់បច្ចុប្បន្ន ដោយមានវិនិយោគក្នុងវិស័យសំខាន់ៗចំនួន៨ រួមមាន កសិកម្ម-ចំណីអាហារ (៥ក្រុមហ៊ុន) វិស័យលក់រាយ (៤ក្រុមហ៊ុន) វិស័យទូរគមនាគមន៍ និងប្រព័ន្ធផ្សព្វផ្សាយ (១ក្រុមហ៊ុន) វិស័យពាណិជ្ជកម្មអេឡិចត្រូនិក និងឌីជីថល (២ក្រុមហ៊ុន) វិស័យអចលនទ្រព្យ (១ក្រុមហ៊ុន) វិស័យឧស្សាហកម្មយានយន្ត(៣ក្រុមហ៊ុន) វិស័យសុខាភិបាល (១ក្រុមហ៊ុន) និងវិស័យហិរញ្ញវត្ថុ (២ក្រុមហ៊ុន)។ ក្រុមហ៊ុន Charoen Pokphand Group មានវិនិយោគនៅប្រទេសចំនួន ៣០ ទូទាំងសកលលោក ភាគច្រើនគឺនៅតំបន់អាស៊ី ។ លោក Dhanin បានប្រកាន់ខ្ជាប់នូវគោលការណ៍សំខាន់មួយក្នុងការរកស៊ី ដែលលោកបានហៅថា គោលការណ៍ប្រយោជន៍ទាំងបី (3 Benefit) គឺបង្កើតវិបុលភាពសម្រាប់ប្រទេស សហគមន៍មូលដ្ឋាន ក៏ដូចជា ក្រុមហ៊ុន និងបុគ្គលិក។ ចំពោះការដឹកនាំវិញ លោក Dhanin Chearavanont ឱ្យតម្លៃខ្ពស់លើធនធានមនុស្ស ដោយលោកបានលើកឡើងជាទស្សនៈថា «**មនុស្សរបស់យើង គឺជាសសរទ្រូងដ៏សំខាន់បំផុតសម្រាប់អនាគតរបស់យើង។ ដើម្បីអាចឈរជើងរឹងមាំបាន យើងត្រូវការអ្នកដឹកនាំជំនាន់ថ្មី ដែលពោរពេញដោយសមត្ថភាពនិងចំណេះដឹង ដើម្បីគ្រប់គ្រង និងដឹកនាំ ស្ថាប័នឆ្ពោះទៅមុខកាន់តែឆ្ងាយជាមួយគ្នា**»។




**3-Benefit Principles of Mr. Dhanin Chearavanont**

លោក Dhanin Chearavanont ត្រូវបានគេស្គាល់ថាជាម្ចាស់ក្រុមហ៊ុន CP Group ដែលជាប់ឈ្មោះជាអ្នកមានលំដាប់ថ្នាក់លេខ១ ប្រចាំប្រទេសថៃ និងជាប្រធានក្រុមប្រឹក្សាភិបាលជាន់ខ្ពស់របស់ក្រុមហ៊ុន Charoen Pokphand Group ។

បន្ទាប់ពីការរីកចម្រើនយ៉ាងឆាប់រហ័សនៅប្រទេសថៃ ក្រុមហ៊ុន Charoen Pokphand Group (CP Group) បានពង្រីកអាជីវកម្មរបស់ខ្លួនទៅកាន់ប្រទេសផ្សេងៗក្នុងតំបន់ អាស៊ាន។ ក្នុងចំណោមទីផ្សារទាំងនេះ ប្រទេសកម្ពុជា គឺជាតំបន់ដែលមានសក្តានុពលខ្លាំងសម្រាប់ការវិនិយោគនៅក្នុងវិស័យកសិកម្ម និងឧស្សាហកម្មអាហារ។

នៅឆ្នាំ ១៩៩៦ ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់ ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន CP Group ត្រូវបានបង្កើតឡើង ដើម្បីចូលរួមអភិវឌ្ឍវិស័យកសិកម្ម និងឧស្សាហកម្មអាហារនៅកម្ពុជា។ គោលដៅចម្បងរបស់ក្រុមហ៊ុនគឺផ្តល់ជូននូវម៉ូឌែលអាជីវកម្ម "ចំណីសត្វ-កសិដ្ឋាន-អាហារ (Feed-Farm-Food)" ដែលមានការផលិតចំណីសត្វមានគុណភាពខ្ពស់ ការចិញ្ចឹមសត្វបែបទំនើប និងការកែច្នៃផលិតផលអាហារដែលមានសុវត្ថិភាព និងគុណភាពខ្ពស់។ ដំណើររបស់ ស៊ី.ភី. ខេមបូឌា បានចាប់ផ្តើមពីការបង្កើតរោងចក្រផលិតអាហារសត្វដំបូង និងការអភិវឌ្ឍការចិញ្ចឹមសត្វជ្រូក និងមាន់។ ក្នុងអំឡុងពេលជាង ២៥ឆ្នាំ មកនេះ ក្រុមហ៊ុនបានពង្រីកអាជីវកម្មរបស់ខ្លួនទៅក្នុងវិស័យ កសិកម្មទឹក ការផលិត ការចែកចាយអាហារ និងការបង្កើតហាងលក់រាយដូចជា CP Five Star, CP Fresh mart ,CP Fresh Shop, Star Coffee និង Hi-Pork ជាដើម។

**អាជីវកម្ម និងផលិតផលមួយចំនួន**
**របស់ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់**



អាជីវកម្មចិញ្ចឹមសត្វ



ស៊ីភី ហ្វាយស្តារ៍


អាជីវកម្មផលិតចំណីសត្វ



ស៊ីភី ហ្វ្រេស ហ្សប



អាជីវកម្មផលិតចំណីអាហារ

បើយោងតាមរបាយការណ៍កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ បានបង្ហាញថាក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា បានបោះទុនវិនិយោគប្រមាណ ៦៧,៤ លានដុល្លារអាមេរិក ទៅលើដំណើរការអាជីវកម្ម កសិ-ឧស្សាហកម្ម និងចំណីអាហារគ្រប់ប្រភេទ រួមទាំងបសុសត្វ និងអាជីវកម្មផ្នែកវារីវប្បកម្ម ហើយប្រភេទសត្វចម្បងៗ មានជាអាទិ៍ ជ្រូក មាន់សាច់ មាន់ស្រុក មាន់ពង និងត្រី[14]។ ក្រៅពីនេះក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ក៏បានវិនិយោគក្នុងវិស័យកសិកម្មទឹក (Aquaculture) ជាពិសេស ការចិញ្ចឹមត្រី និងបង្គារ ដើម្បីបង្កើនសុវត្ថិភាពចំណីអាហារ កាត់បន្ថយការពឹងផ្អែកលើការនាំចូលពីក្រៅប្រទេស និងជាការចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងបង្កើតឱកាសការងារជូនប្រជាកសិករខ្មែរ។

បន្ថែមលើនេះ ស៊ី.ភី. ខេមបូឌា ក៏បានបោះការវិនិយោគយ៉ាងខ្លាំងក្នុង វិស័យកែច្នៃអាហារ និងការចែកចាយ ដោយបង្កើតរោងចក្រកែច្នៃសាច់សត្វ និងសាច់ជ្រូកនៅខេត្តកំពត ដែលផលិតផលិតផលកែច្នៃមានដូច

ជាសាច់ក្រក ប្រហិត និងសាច់ប៉ាត់តេ ដោយគិតជាមធ្យមក្នុងមួយខែរោងចក្រអាចផលិតបាន ៥០០,០០០ គ.ក្រ ដើម្បីផ្គត់ផ្គង់អាហារដែលមានគុណភាពខ្ពស់ អនាម័យ និងមានសុវត្ថិភាពជូនប្រជាជនខ្មែរ។ ក្រុមហ៊ុនបានបង្កើតប្រព័ន្ធផ្គត់ផ្គង់ទំនើប ដែលអាចបម្រើទីផ្សារនៅក្នុងស្រុក និងជម្រុញការនាំចេញផងដែរ។

លើសពីនេះ បច្ចុប្បន្នក្រុមហ៊ុនមានរោងចក្រផលិតចំណីសត្វពីរកន្លែង គឺទីមួយនៅខេត្តកំពង់ស្ពឺ និងទីពីរនៅខេត្តប៉ៃលិន រោងចក្រទាំងពីរនេះមានសក្តានុពលផលិតចំណីសត្វគ្រប់ប្រភេទបានចំនួន ៥៥,០០០តោន/ខែ ដោយប្រើប្រាស់វត្ថុធាតុដើមផលិតក្នុងស្រុកមានពោតក្រហមចំនួន ២០០,០០០តោន/ឆ្នាំ និងដំឡូងមីក្រៀមចំនួន ១០០,០០០តោន/ឆ្នាំ។

ក្រៅពីផលិតកម្មចំណីសត្វ ក្រុមហ៊ុនមានចិញ្ចឹមមាន់ពូជយកពងភ្ញាស់យកកូនបានចំនួន ៧០០,០០០ក្បាល/សប្តាហ៍ ផលិតកូនជ្រូកពូជបានចំនួន ២០,០០០ក្បាល/សប្តាហ៍។ ដើម្បីបំពេញតម្រូវការសាច់មាន់ និងផលិតផលសាច់ ក្រុមហ៊ុនបានបង្កើតសត្តឃាតដ្ឋានមាន់មួយកន្លែង ដែលអាចពិឃាតមាន់សាច់បានចំនួន ១០,០០០ក្បាល/ថ្ងៃ មួយផ្នែកលក់ជាសាច់មាន់ស្រស់ និងមួយផ្នែកទៀតលក់ជាផលិតផលកែច្នៃ។

ជាមួយគោលបំណងពង្រីកផលិតកម្មចិញ្ចឹមសត្វ ជាពិសេសចូលរួមលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ ក្រុមហ៊ុនបានអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ដោយគិតមកទល់ដើមឆ្នាំ២០២១ ក្រុមហ៊ុនមានដៃគូសហការចិញ្ចឹមជ្រូក និងមាន់ចំនួន ១,៤០០គ្រួសារ នៅទូទាំងប្រទេស។ ម៉្យាងវិញទៀត តាមផែនការគ្រោងទុក ក្រុមហ៊ុននឹងបង្កើនផលិតភាពផលិតកម្មសត្វ និងចំណីឱ្យបានពី១៥% ទៅ ២០% ដើម្បីចូលរួមផ្គត់ផ្គង់ឱ្យតម្រូវការទីផ្សារក្នុងស្រុកដែលចេះតែមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ និងអាចធ្វើការនាំចេញផងដែរ។ ស៊ី.ភី. ខេមបូឌា បានផ្តល់សារសំខាន់លើការអភិរក្សបរិស្ថាន និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយសហការជាមួយកសិករក្នុងស្រុក និងប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយអភិវឌ្ឍន៍ ដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាពផលិតផល។






**រោងចក្រកែច្នៃផលិតផលអាហារ**
**របស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំការ ខេត្តកំពត**

### ៣.១.២ ចក្ខុវិស័យ បេសកកម្ម ការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់

### ក. ចក្ខុវិស័យ

ចក្ខុវិស័យរបស់ក្រុមហ៊ុន ជាគោលដៅឆ្ពោះទៅរក " **ផ្ទះបាយពិភពលោក** " ។ ក្រុមហ៊ុនបានផ្តល់ភាពសំខាន់ដោយផ្តោតទៅលើការស្រាវជ្រាវ មុនពេលផលិត និងរាល់ដំណាក់កាលនីមួយៗត្រូវបានអភិវឌ្ឍក្នុងប្រតិបត្តិការងារឱ្យមានប្រសិទ្ធភាពល្អ ដើម្បីឱ្យផលិតផលចំណីអាហារស្របទៅតាមស្តង់ដារដែលមានគុណភាពខ្ពស់ និងយល់ពីចំណង់ចំណូលចិត្តរបស់អតិថិជនដែលជាអ្នកបរិភោគ ដោយពឹងផ្អែកលើគោលនយោបាយប្រតិបត្តិការអាជីវកម្មក្នុងរូបភាពដែលមិនផ្តល់ផលប៉ះពាល់ដល់បរិស្ថាន និងសុខភាពរបស់ប្រជាជន។ ម្យ៉ាងវិញទៀតក្រុមហ៊ុនយើងមានចក្ខុវិស័យច្បាស់លាស់ ក្នុងការកសាងអាជីវកម្មមួយប្រកបដោយនិរន្តភាព និងដើម្បីអភិវឌ្ឍកសាងអនាគតរួមគ្នាជាផ្លូវមួយឆ្ពោះទៅរកការរីកចម្រើន ហើយមិនតែប៉ុណ្ណោះក្រុមហ៊ុនថែមទាំងបានលើកស្ទួយដល់ការរស់នៅរបស់ប្រជាជន សហគមន៍ និងពិភពលោកទាំងមូលផងដែរ។

### ខ. បេសកកម្ម

ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់ គឺជាក្រុមហ៊ុនមួយដែលឆ្លើយតបទៅនឹងការរំពឹងទុកដែលជាសេចក្តីត្រូវការរបស់អតិថិជន ដើម្បីនាំមកនូវការផលិត ការអភិវឌ្ឍ និងការកែច្នៃឥតឈប់ឈរសម្រាប់អតិថិជនព្រមទាំងក្រុមហ៊ុនផងដែរ។ យ៉ាងណាមិញក្រុមហ៊ុនបានប្រកាន់ខ្ជាប់នូវទស្សនវិស័យ ចំណេញបីយ៉ាង (3-Benefit) គឺបង្កើតវិបុលភាពសម្រាប់ប្រទេស សហគមន៍មូលដ្ឋាន ក៏ដូចជាក្រុមហ៊ុន និងបុគ្គលិកដែលមានគោលបំណងបង្កើតតម្លៃសម្រាប់ប្រទេសជាតិទាំងមូល សហគមន៍ និងអង្គភាពផ្ទាល់ខ្លួន ហើយព្រមទាំងបង្កើតការចូលរួមប្រើប្រាស់របស់អតិថិជនជាមួយផលិតផលប្រកបដោយភាពច្នៃប្រឌិត និងបង្កើតទំនាក់ទំនងល្អជាមួយសង្គមផងដែរ។ លើសពីនេះទៅទៀតក្រុមហ៊ុន មានគោលដៅកែប្រែជីវភាពរស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរជាងមុន ដែលគិតចាប់ពីបុគ្គលិករបស់ខ្លួន អ្នកដែលមានទំនាក់ទំនងជាមួយអាជីវកម្មរបស់ក្រុមហ៊ុន រហូតដល់សហគមន៍ជាច្រើនផ្សេងៗទៀត ហើយតំណាងអាជីវកម្មក្រុមហ៊ុនក៏មានអភិបាលកិច្ចល្អ តម្លាភាព ការទទួលខុសត្រូវសង្គមស្របតាមបទបញ្ញា និងស្តង់ដារជាតិ និងអន្តរជាតិ។

### គ. ការប្តេជ្ញាចិត្ត

ស៊ី.ភី. ខេមបូឌា បានប្តេជ្ញាចិត្តផ្តល់ផលិតផលអាហារ និងអាហារសត្វដែលមានគុណភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ ដើម្បីធានាសុខភាពសន្តិសុខស្បៀងសម្រាប់ប្រជាជនកម្ពុជា និងលើកកម្ពស់វិស័យកសិកម្មចីរភាព។ ក្រុមហ៊ុនសហការជាមួយកសិករដើម្បីផ្តល់បច្ចេកវិទ្យា និងការបណ្តុះបណ្តាលសម្រាប់ផលិតភាពប្រសើរ ព្រមទាំងផ្គត់ផ្គង់សាច់សត្វមានសុវត្ថិភាពដោយប្រព័ន្ធគ្រប់គ្រងគុណភាព។ ស៊ី.ភី. បានបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនតាមរយៈកម្មវិធីជាច្រើនដូចជា ការផ្តល់ជំនួយសង្គម និងការលើកកម្ពស់ការអប់រំ។ C.P. Cambodia នៅតែបន្តធ្វើឱ្យប្រសើរឡើងនូវវិស័យកសិកម្ម និងឧស្សាហកម្មអាហារ ដោយផ្តោតលើគុណភាព វិវត្តន៍បច្ចេកវិទ្យា និងការចូលរួមអភិវឌ្ឍសង្គម ដើម្បីផ្តល់ផលិតផលសុវត្ថិភាព និងប្រកបដោយទំនួលខុសត្រូវសម្រាប់ទីផ្សារកម្ពុជា។

យោងតាមប្រសាសន៍របស់លោក Wittaya Kreangkriwit អគ្គនាយកក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា បានថ្លែងនៅក្នុងដំណើរទស្សនកិច្ចរបស់លោកបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ទៅកាន់រោងចក្រកែច្នៃផលិតផលអាហារ និងបំលែងសាច់មាន់ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់ ថា ក្រុមហ៊ុន ស៊ី.ភី. ផ្តោតសំខាន់ទៅលើការ

អភិវឌ្ឍន៍ស្តង់ដារផលិតកម្មចំណីអាហារ ទាំងគុណភាព និងបរិមាណ ដើម្បីបំពេញតម្រូវការទីផ្សារ។ ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់ រីករាយក្នុងការសហការ ជាមួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការចែករំលែកចំណេះដឹងទាក់ទងនឹងសុវត្ថិភាពចំណីអាហារដល់យុវជន និងប្រជាជនកម្ពុជា។

បន្ថែមពីនេះលោក Thanachit Sriboonlue នាយករងគ្រប់គ្រង ក៏បានមានប្រសាសន៍ថា ក្រុមហ៊ុនស៊ី.ភី. ប្តេជ្ញាផ្តល់នូវផលិតផលអាហារប្រកបដោយគុណភាព អនាម័យសុវត្ថិភាព និងអាហារូបត្ថម្ភខ្ពស់ដល់ប្រជាជនកម្ពុជា។ អ្នកបរិភោគទាំងអស់អាចជឿជាក់លើផលិតផលស៊ី.ភី. បានព្រោះថាគ្រប់ផលិតផលចំណីអាហារទាំងអស់របស់ក្រុមហ៊ុនទទួលបានស្តង់ដារអន្តរជាតិ ដែលមានការត្រួតពិនិត្យត្រឹមត្រូវតាមបែបបច្ចេកទេសដូចជាស្តង់ដារ GHP, HACCP និង HALAL លោកអ្នកអាចបរិភោគដោយភាពជឿជាក់ «អាហារសុវត្ថិភាពជឿជាក់លើស៊ី.ភី»។

### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់

#### ក. រចនាសម្ព័ន្ធគ្រប់គ្រង

រចនាសម្ព័ន្ធការងារពិតជាមានសារៈសំខាន់ក្នុងការធ្វើប្រតិបត្តិការអាជីវកម្មប្រកបដោយប្រសិទ្ធិភាពខ្ពស់ ជាពិសេសសម្រាប់ក្រុមហ៊ុនផលិតកម្ម ដើម្បីធានាបាននូវគុណភាពផលិតកម្ម ទប់ស្កាត់ហានិភ័យ និងបង្កើនការប្រកួតប្រជែងក្នុងទីផ្សារ។ រចនាសម្ព័ន្ធល្អអាចជម្រុញការរីកចម្រើនប្រកបដោយចីរភាព ដោយធានាឱ្យក្រុមហ៊ុនមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធាន និងការផលិត។ ខាងក្រោមនេះជារចនាសម្ព័ន្ធគ្រប់គ្រងអាជីវកម្ម ដែលបានដកស្រង់ចេញពីសៀវភៅនៅក្នុងបណ្ណាល័យ៖

## រចនាសម្ព័ន្ធគ្រប់គ្រងអាជីវកម្ម



ដោយសារតែ C.P. Cambodia ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ Charoen Pokphand Foods (CPF) រចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួនអាចត្រូវបានប្រតិបត្តិទៅតាមគំរូរបស់ក្រុមហ៊ុនធំ។ យោងទៅតាមការសិក្សាស្រាវជ្រាវពីមានរចនាសម្ព័ន្ធគ្រប់គ្រងរបស់ CPF យើងអាចដឹងបានថាក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់ អាចមានរចនាសម្ព័ន្ធគ្រប់គ្រងដែលត្រូវបានបែងចែកទៅតាមផ្នែកអាជីវកម្ម និងផ្នែកគ្រប់គ្រង ប្រកបដោយវិជ្ជាជីវៈដូចទៅនឹងក្រុមហ៊ុនមេដែរ។ ខាងក្រោមនេះគឺជារចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន Charoen Pokphand Foods (CPF)៖



## ខ. តួនាទី និងភារកិច្ច

ដើម្បីសម្រេចបាននូវគោលដៅ និងការប្តេជ្ញាចិត្តរបស់ខ្លួន និងគណៈគ្រប់គ្រងទាំងអស់ ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់ បានបែងចែកតួនាទី និងភារកិច្ចទៅតាមផ្នែកអាជីវកម្ម និងផ្នែកគ្រប់គ្រងផ្សេងៗគ្នា ដើម្បីជានាថាការប្រតិបត្តិអាជីវកម្មអាចដំណើរការបានដោយមានប្រសិទ្ធភាព និងភាពច្បាស់លាស់ក្នុងការអនុវត្តការងារដូចខាងក្រោម៖

**១. គណៈគ្រប់គ្រងកំពូល (Top Management)**

➢ ប្រធានប្រតិបត្តិ (Chief Executive Officer - CEO) / Country Managing Director

- ទទួលខុសត្រូវ លើទិសដៅយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន
- រាយការណ៍ទៅ CP Group នៅថៃ ឬតំបន់អាស៊ីអាគ្នេយ៍

➢ ក្រុមប្រឹក្សាភិបាល (Board of Directors - BOD)

- ត្រួតពិនិត្យសំណុំគោលនយោបាយ និងផ្តល់ទិសដៅអាជីវកម្ម
- ត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍អាជីវកម្ម

**២. ផ្នែកអាជីវកម្មសំខាន់ៗ (Core Business Units)**

ក្រុមហ៊ុន CP Cambodia ចែកចេញជា ៣ ផ្នែកអាជីវកម្មធំៗ៖

**២.១. ផ្នែកកសិកម្ម និងអាហារសត្វ (Agro-Industrial & Feed Business)**

➢ ឧស្សាហកម្មអាហារសត្វ (Feed Mill Division)

- ផលិត និងចែកចាយអាហារសត្វសម្រាប់សត្វមានជើង និងសត្វជលផល

➢ ការចិញ្ចឹមសត្វ និងចំការកសិកម្ម (Livestock & Aquaculture Division)

- ចិញ្ចឹមមាន់, ទា, និងជ្រូក
- កិច្ចសហប្រតិបត្តិការជាមួយកសិករដែលមានកិច្ចសន្យា (Contract Farming)

➢ កសិកម្ម និងគ្រាប់ពូជ (Crop & Seed Business)

- ផ្គត់ផ្គង់គ្រាប់ពូជ និងបច្ចេកវិទ្យាកសិកម្ម

**២.២. ផ្នែកកែច្នៃចំណីអាហារ (Food Processing)**

➢ ផលិតកម្ម និងរោងចក្រអាហារ (Food Processing Factory)

- ផលិតអាហារដែលរួចជាស្រេច (Ready-to-Eat Foods)
- ផលិតសាច់ដុតស្រោប និងផលិតផលបែបថៃ

➢ អាជីវកម្មលក់រាយ និងចែកចាយ (Retail & Distribution Business)

- ផ្គត់ផ្គង់អាហារជូនសាធារណៈជន និងអាជីវកម្ម (B2B & B2C Distribution)

**២.៣. ផ្នែកលក់រាយ និងចែកចាយ (Retail & Wholesale Business)**

➢ ការចែកចាយទំនិញតាមផ្លូវទំនាក់ទំនងអាជីវកម្ម (B2B)

- ការប្រតិបត្តិ CP Fresh Mart និងហាងលក់រាយ

**៣. ផ្នែកគ្រប់គ្រង និងអនុសាខា (Corporate & Support Functions)**

ក្រុមហ៊ុន CP Cambodia មានផ្នែកគ្រប់គ្រងគាំទ្រដែលជួយគ្រប់គ្រងអាជីវកម្មសរុប៖

### ៣.១. ផ្នែកហិរញ្ញវត្ថុ (Finance & Accounting)

- ➢ គ្រប់គ្រងថវិកា និងរបាយការណ៍ហិរញ្ញវត្ថុ
- ➢ គ្រប់គ្រងចំណាយ និងផ្តល់ការវិភាគហិរញ្ញវត្ថុ
- ➢ កត់ត្រាប្រតិបត្តិការចំណូល ចំណាយ ជាប្រចាំខែ និងប្រចាំឆ្នាំ
- ➢ ទូទាត់រាល់ការចំណាយប្រចាំថ្ងៃ ឬប្រចាំខែ
- ➢ រៀបចំប្រាក់បៀវត្សបុគ្គលិក
- ➢ ប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ

## រចនាសម្ព័ន្ធផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ




### ៣.២. ផ្នែកធនធានមនុស្ស និងរដ្ឋបាល (Human Resources & Administration)

- ការជ្រើសរើសបុគ្គលិក និងការអភិវឌ្ឍជំនាញ
- ការគ្រប់គ្រងបរិស្ថានការងារ និងការអនុលោមតាមបទដ្ឋាន

### ៣.៣. ផ្នែកលក់ និងទីផ្សារ (Sales & Marketing)

- ផ្សព្វផ្សាយផលិតផល និងយុទ្ធសាស្ត្រទីផ្សារ
- គ្រប់គ្រងទំនាក់ទំនងអតិថិជន និងការចងសម្ព័ន្ធអាជីវកម្ម

### ៣.៤. ផ្នែកផ្គត់ផ្គង់ និងខ្សែសង្វាក់ចែកចាយ (Supply Chain & Procurement)

- គ្រប់គ្រងស្តុក និងការដឹកជញ្ជូន
- តាមដានកិច្ចសន្យាផ្គត់ផ្គង់ និងការដាក់ពាក្យបញ្ជាទិញ

### ៣.៥. ផ្នែកបច្ចេកវិទ្យាព័ត៌មាន (IT & Digital Transformation)

- អភិវឌ្ឍបច្ចេកវិទ្យា ERP និងគ្រប់គ្រងទិន្នន័យ
- ឆ្លើយតបទៅនឹងការរីកចម្រើននៃឌីជីថលក្នុងអាជីវកម្ម

### ៣.៦. ផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ (Research & Development - R&D)

- ស្រាវជ្រាវអាហារសត្វ និងបច្ចេកវិទ្យាកសិកម្ម
- ការបង្កើតផលិតផលថ្មីៗសម្រាប់ទីផ្សារ

### ៤. ផ្នែកសាខា និងរោងចក្រ (Regional Operations & Factories)

ក្រុមហ៊ុន CP Cambodia មានបណ្តាញអាជីវកម្មទូទាំងប្រទេស៖

- រោងចក្រអាហារសត្វ (Feed Mills) នៅក្នុងខេត្តសំខាន់ៗ
- កសិដ្ឋាន និងកន្លែងចិញ្ចឹមសត្វ (Farms & Hatcheries)
- រដ្ឋបាលសាខា (Regional Offices) ដើម្បីគ្រប់គ្រងអាជីវកម្មនៅតំបន់ផ្សេងៗ។

## ៣.២ នីតិវិធីនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់

### ៣.២.១ ការកំណត់គោលដៅ

ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា មានការកំណត់គោលដៅយ៉ាងច្បាស់មុននឹងរៀបចំគម្រោងថវិកាដើម្បីធានាថាការវិនិយោគ និងសកម្មភាពអាជីវកម្មនានា អាចជួយជម្រុញដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ គោលដៅសំខាន់ៗរបស់ក្រុមហ៊ុន ស៊ី.ភី. មានផ្អែកលើ ក្របខ័ណ្ឌ 3Hs (Heart, Health, Home) ដែលគ្របដណ្តប់លើផ្នែកសេដ្ឋកិច្ច, សង្គម, និងបរិស្ថាន ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍របស់ខ្លួន។

មុននឹងរៀបចំគម្រោងថវិកា ក្នុងឆ្នាំនីមួយៗ ស៊ី.ភី. មានការបែងចែកគោលដៅចម្បងដើម្បីធានាការអនុវត្តការងារស្របទៅតាមទស្សនៈវិស័យ និងបេសកកម្មរបស់ក្រុមហ៊ុនដូចខាងក្រោម៖

#### ក. ការកំណត់គោលបំណងនៃការចំណាយ

✧ **ការបង្កើនផលិតភាព និងចំណូល**: ផ្តោតលើការអភិវឌ្ឍផលិតកម្មកសិកម្ម និងឧស្សាហកម្ម ដើម្បីលើកកម្ពស់ចំណូល និងបង្កើនការងារ។

✧ **ការចងសម្ពន្ធភាពជាមួយភាគីពាក់ព័ន្ធ**: ស៊ី.ភី. ខេមបូឌា ទាក់ទាញសហការជាមួយភាគីពាក់ព័ន្ធ ដូចជា រដ្ឋាភិបាល អង្គការអន្តរជាតិ និងសហគមន៍ ដើម្បីធានាការអភិវឌ្ឍដែលប្រសើរជាងមុន។

✧ **ការសម្របសម្រួល និងអភិវឌ្ឍន៍ចីរភាព**: ក្រុមហ៊ុនផ្តោតលើការកាត់បន្ថយផលប៉ះពាល់បរិស្ថាន ការកែលម្អសុខុមាលភាពនៃកម្មករ និងការអភិវឌ្ឍសហគមន៍។

✧ **ការអភិវឌ្ឍបច្ចេកវិទ្យា និងចំណេះដឹង**: ក្រុមហ៊ុនវិនិយោគលើបច្ចេកវិទ្យាបច្ចុប្បន្ន និងកម្មវិធីបណ្តុះបណ្តាល ដើម្បីធ្វើឱ្យកិច្ចប្រតិបត្តិមានប្រសិទ្ធភាព។

✧ **ការអភិវឌ្ឍធនធានមនុស្ស**: ក្រុមហ៊ុនបានវិនិយោគលើការអប់រំ និងការអភិវឌ្ឍជំនាញអាជីពបុគ្គលិកស៊ី.ភី. និងយុវជនជាសកល ដោយផ្តល់អាហារូបករណ៍ដល់សិស្សនិស្សិត និងលើកកម្ពស់សមត្ថភាពថ្នាក់ដឹកនាំ និងជំនាញថ្មីៗទាក់ទងនឹងបច្ចេកវិទ្យា។

✧ **គោលនយោបាយអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច**: ដោយក្រុមហ៊ុនសហការជាមួយអ្នកផលិតក្នុងស្រុក និងបង្កើតកសិកម្មប្រកបដោយប្រសិទ្ធភាព គាំទ្រការអភិវឌ្ឍឧស្សាហកម្មកសិកម្ម និងបង្កើតប្រព័ន្ធផលិតផលប្រកបដោយនិរន្តរភាព។

#### ខ. ស្តង់ដារក្នុងការចំណាយ

✧ ធ្វើវាឱ្យទៅជាដំណើរការនៃការប្រាស្រ័យទាក់ទង និងព្រមព្រៀងគ្នារវាងផ្នែកមួយទៅផ្នែកមួយទៀត ក្នុងគោលបំណងដែលអាចផ្តល់បាននូវព័ត៌មានចំណាយដែលជាក់លាក់មួយ។

✧ ចំពោះចំណាយនីមួយៗ ដែលបានស្នើចូលគម្រោងតាមផ្នែកត្រូវគិតពីភាពសមហេតុផល និងមានលក្ខណៈច្បាស់លាស់ ដែលបានសិក្សារួចជាស្រេចពីទំហំនៃថវិកាដែលត្រូវស្នើឡើង។

✧ ចំណាយទៅតាមផ្នែកទាំងអស់ ជាកញ្ចប់ថវិកាប្រើសម្រាប់ឆ្លើយតបទៅនឹងការអនុវត្តការងារប្រកប ដោយប្រសិទ្ធភាព ភ្ជាប់ទៅនឹងបំណងប្រាថ្នាដែលក្រុមហ៊ុនចង់បាន។

✧ ចំពោះគ្រប់ផ្នែកទាំងអស់ត្រូវគិតពីភាពចាំបាច់ជាជម្រើសចម្បង។

**៣.២.២ ការដាក់ផែនការ និងការប៉ាន់ស្មានចំណាយ**

ក្រុមក្រុមហ៊ុន ស៊ីភី ខេមបូឌា មានសម្ព័ន្ធភាពជាមួយក្រុមហ៊ុន ស៊ីភី ផ្សេងទៀតក្នុងចំណោមប្រទេសជាង ១៦ ដែលចែកចាយផលិតផលរបស់ខ្លួនទៅកាន់ជាង ៤០ប្រទេសនៅជុំវិញពិភពលោក។ តាមគោលការណ៍ប្រកបដោយនិរន្តរភាព ស៊ី.ភី. ខេមបូឌា បានយកចិត្តទុកយ៉ាងខ្លាំងក្នុងការជួយដល់កសិករក្នុងស្រុក និងការកាត់បន្ថយការ ចំណាយលើមធ្យោបាយធ្វើដំណើរដែលជាមូលហេតុដែលយើងផ្តល់អាទិភាពដល់ផលិតផលវត្ថុធាតុដើមក្នុងស្រុកជាពិសេស ធានាបាននូវការរួមបញ្ចូលនូវជីវជាតិបំប៉ន រួមទាំងការផលិតប្រកបដោយគុណភាពខ្ពស់ និងឈានមុខគេ។

ការប៉ាន់ស្មានការចំណាយសម្រាប់អាជីវកម្ម ការគ្រោងទុកនូវចំណាយ គឺសំខាន់ដើម្បីដឹងថាអាជីវកម្មត្រូវការវិនិយោគ ការចំណាយយ៉ាងដូចម្តេចខ្លះ។ ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា មានការប៉ាន់ស្មានចំណាយ និងរៀបចំគម្រោងថវិកាតាមរយៈការអនុវត្តគោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុដែលមានដូចជា ប្រភពចំណាយ ចំណាយផ្ទាល់ ចំណាយប្រយោល។

**ក. ប្រភពចំណាយ**

ក្រុមហ៊ុន ស៊ី.ភី. គឺជាក្រុមហ៊ុនឈានមុខគេផ្នែកកសិកម្ម និងកសិ-ឧស្សាហកម្មនៅក្នុងតំបន់អាស៊ី ប៉ាស៊ីហ្វិក។ ស៊ី.ភី. ខេមបូឌា កំពុងតែធ្វើការវិនិយោគក្នុងទំហំទឹកប្រាក់ជាង ៦៧ លានដុល្លារ លើផលិតកម្ម សត្វ ការកែច្នៃចំណីអាហារ និងសត្តឃាតដ្ឋាននៅកម្ពុជា។ ហើយការវិនិយោគនេះ គឺស្របទៅនឹងគោលនយោបាយ និងផែនការអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣ នេះបើតាមឱ្យដឹងពីលោក វេង សា ខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ហើយថ្មីៗនេះដែរ ក្រុមហ៊ុនបានវិនិយោគក្នុងការ អភិវឌ្ឍរោងចក្រស៊ីឡូ និងសម្ងួតពោតនៅខេត្តប៉ៃលិនភាគខាងលិចប្រទេសកម្ពុជា។ ការវិនិយោគនេះគឺ ដើម្បីធានានូវវត្ថុធាតុដើមដែលមានគុណភាពខ្ពស់ ដើម្បីបម្រើដល់ការផលិតចំណីរបស់ខ្លួនសម្រាប់ទាំង ទីផ្សារក្នុងស្រុក និងការនាំចេញ។ ចាប់តាំងពីឆ្នាំ១៩៩៥ មកក្រុមហ៊ុន ស៊ី.ភី. បានបណ្តាក់ទុនសរុបចំនួន ៣ ពាន់លានបាតក្នុងការផលិតចំណីសត្វ ការចិញ្ចឹមសត្វ និងការកែច្នៃម្ហូបអាហារ។ ការមានរោងចក្រនៅទីនោះនឹងកាត់បន្ថយការចំណាយលើការដឹកជញ្ជូន។ ដំបូងឡើយសមត្ថភាពត្រូវបានកំណត់ត្រឹម ១០.០០០តោនក្នុងមួយខែ។ ក្រុមហ៊ុនក៏កំពុងពិចារណាលើការវិនិយោគលើវារីវប្បកម្មនៅកម្ពុជានាពេលខាងមុខផងដែរ។

**ខ. ចំណាយផ្ទាល់**

ការចំណាយដោយផ្ទាល់ គឺជាទំរង់នៃការវិភាគថ្លៃដើមដែលប្រើតែថ្លៃដើមថេរដើម្បីធ្វើការសម្រេច ចិត្តវាមិនបានរាប់បញ្ចូលចំណាយអថេរទេ ពីព្រោះត្រូវបានគេសន្មត់ថា ចំណាយនេះបានផ្សារភ្ជាប់ជាមួយនឹងពេលវេលានៃកម្លាំងពលកម្ម ក្នុងនោះដែរយើងឃើញថាក្រុមហ៊ុនមានចំណាយផ្ទាល់ចំនួន៣ ធំៗ គឺចំណាយលើវត្ថុធាតុដើម ចំណាយលើកម្លាំងពលកម្ម និងចំណាយប្រតិបត្តការប្រចាំថ្ងៃ។ បើយោង តាមការបង្ហោះនៅលើគេហទំព័រហ្វេសប៊ុកផ្លូវការរបស់ លោក វេង សាខុន បានឱ្យដឹងថាក្រុមហ៊ុន ស៊ីភី កម្ពុជា ជាក្រុមហ៊ុននាំមុខធំមួយក្នុងចំណោមក្រុមហ៊ុនធំៗ ដែលបាននឹងកំពុងដំណើរការអាជីវកម្មលើវិស័យផលិតកម្មសត្វ (ជ្រូក និងមាន់) ស៊ុត

មាន់ ចំណីសត្វ និងអាហារមនុស្ស(សាច់ក្រក ប្រហិត និង សាច់ប៉ាត់តេ)។ លោកបន្តទៀតថា បច្ចុប្បន្នក្រុមហ៊ុនមានរោងចក្រផលិតចំណីសត្វពីរកន្លែងមួយស្ថិតនៅខេត្តកំពង់ស្ពឺ និងមួយទៀតនៅខេត្តប៉ៃលិនដែលរោងចក្រទាំងពីរមានសក្តានុពលផលិតចំណីសត្វគ្រប់ប្រភេទបានចំនួន ៥៥,០០០តោន/ខែ ដោយប្រើប្រាស់វត្ថុធាតុដើមផលិតក្នុងស្រុកមានពោតក្រហមចំនួន ២០០,០០០តោន/ឆ្នាំ និងដំឡូងមីក្រៀមចំនួន ១០០,០០០តោន/ក្នុងមួយឆ្នាំ។ លោកបន្ថែមទៀតថា វត្ថុធាតុដើមមួយចំនួនទៀត ក្រុមហ៊ុនបានស្នើសុំគោលការណ៍នាំចូលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីយកមកបំពេញបង្គ្រប់តាមតម្រូវការរបស់រោងចក្រ និងជាពិសេសអតិថិជនដែលជាអ្នក ចិញ្ចឹមសត្វ ម្ចាស់ដេប៉ូចំណីសត្វ ដៃគូ និងប្រើប្រាស់ក្នុងក្រុមហ៊ុនផ្ទាល់ផងដែរ។ ក្រៅពីផលិតកម្មចំណី សត្វ ក្រុមហ៊ុនមានចិញ្ចឹមមាន់ពូជយកពងភ្ញាស់យកកូនបានចំនួន ៧០០,០០០ក្បាល/សប្តាហ៍ ផលិតកូនជ្រូកពូជបានចំនួន ២០,០០០ក្បាល/សប្តាហ៍។ លើសពីនេះលោកបាននិយាយថា៖ «ដើម្បីបំពេញ ឱ្យសេចក្តីត្រូវការ សាច់មាន់ និងផលិតផលសាច់ ក្រុមហ៊ុនបានបង្កើតសត្តឃាតដ្ឋានមាន់មួយកន្លែងដែលអាចពិឃាតមាន់យកសាច់បានចំនួន ១០,០០០ក្បាល/ថ្ងៃ មួយផ្នែកលក់ជាសាច់មាន់ស្រស់ និងមួយផ្នែកទៀតលក់ជាផលិតផលកែច្នៃ មានដូចជាសាច់ក្រក ប្រហិត និងសាច់ប៉ាត់តេ ដោយគិតជា មធ្យមក្នុងមួយខែរោងចក្រអាចផលិតបាន ៥០០,០០០ គ.ក្រ»។ ក្រុមហ៊ុន CP Cambodia ដែលជា ក្រុមហ៊ុនផលិតផលថៃ Charoen Pokphand Company Limited គ្រោងចំណាយទឹកប្រាក់ ៨លានដុល្លារ ដើម្បីបង្កើនចំនួនជ្រូកពីរដងក្នុងកសិដ្ឋានរបស់ខ្លួនក្នុងរយៈពេល ៥ ឆ្នាំក្រោយ ដើម្បីតាមឱ្យទាន់ក្រុមហ៊ុនក្នុងស្រុក។ ដោយយោងតាមរបាយការណ៍នេះយើងឃើញថា រាល់ការចំណាយនីមួយៗត្រូវមានការគ្រោងទុកមុនយ៉ាងច្បាស់លាស់ក្នុងរយៈពេលយ៉ាងតិចបំផុត ១ខែមុន ហើយការចំណាយទាំងអស់ត្រូវមានការដាក់សំណើរស្នើសុំ ពីផ្នែកដែលបានជាប់ទាក់ទង។

**គ. ចំណាយប្រយោល**

ចំណាយប្រយោល គឺជាចំណាយដែលកើតឡើងមិនបានព្រៀងទុកមុន ឬកើតដោយជាយថាហេតុណាមួយ។ ចំណាយប្រយោល វាបានពាក់ព័ន្ធទៅលើការធ្វើចំណាយរំលស់នៃទ្រព្យសកម្មថេរដែលបានប្រើក្នុងការផលិត ហើយក្នុងនោះប្រភេទនៃការចំណាយនេះរួមមានចំនួនទឹកប្រាក់ប្រយោល ដែលធ្វើការចំណាយផ្សេងៗទៀត លើកលែងតែជាចំណាយប្រតិបត្តិការ។ ក្នុងនោះដែរ ក្រុម ហ៊ុនតែងតែបានធ្វើនូវគ្រោងកញ្ចប់ថវិកាមួយផ្នែកដើម្បីត្រៀមសម្រាប់ចំណាយនេះក្នុងគោលបំណង ប្រការទុកជាមុនបើករណី មានតម្រូវការណាមួយកើតឡើងជាយថាហេតុ។ ដែលចំណាយទាំងនោះអាច កើតមានទៅលើ៖

- ការថែទាំ និងជួសជុលបរិក្ខារឧបករណ៍ និងអគារ។
- ការធ្លាក់ចុះនៃឧបករណ៍ និងការដឹកជញ្ជូន។
- ការចំណាយនៃការគ្រប់គ្រងការផ្គត់ផ្គង់ និងសកម្មភាពលទ្ធកម្មហិរញ្ញវត្ថុ និងទីផ្សារ...។

ចំពោះចំណាយដែលកើតឡើងរួច ដើម្បីទទួលបានប្រាក់សម្រាប់ទូទាត់ការចំណាយនេះពី គណនេយ្យយើងត្រូវមានជារូបភាពបង្ហាញពីការខូចខាត និងវិក័យបត្រទៅលើចំណាយដែលកើតឡើង ទៅកាន់ផ្នែកគណនេយ្យករ ដើម្បីគណនេយ្យករបញ្ជូនទៅផ្នែកហិរញ្ញវត្ថុ ផ្នែកហិរញ្ញវត្ថុបានបញ្ជូនបន្តទៅកាន់ក្រុមអ្នកគ្រប់គ្រងដើម្បីធ្វើការសម្រេចចិត្ត រួចបញ្ជូនត្រឡប់មកកាន់ផ្នែកហិរញ្ញវត្ថុវិញ ដើម្បីផ្នែកហិរញ្ញវត្ថុចេញជាសាច់ប្រាក់ជូនគណនេយ្យករយកទៅប្រើប្រាស់។ ចំពោះចំណាយដែលចំបាច់ត្រូវប្រើប្រាស់ជាបន្ទាន់ ឬជាចំណាយ

ណាដែលខ្វះខានពុំបាន គឺយើងត្រូវមានតារាងប្រៀបធៀបតម្លៃរវាងក្រុមហ៊ុនដ៏ទៃពី ២ ទៅ ៣ តារាងបញ្ជូនទៅផ្នែកគណនេយ្យករហើយ ផ្នែកគណនេយ្យករត្រូវបញ្ជូនតារាងទាំងនោះទៅកាន់ផ្នែកគ្រប់គ្រងដើម្បីសម្រេចចិត្ត និងវិភាគជ្រើសរើស យកតារាងមួយណាក្នុងចំណោមតារាងទាំងនោះ។ បន្ទាប់ពីធ្វើការសម្រេចចិត្តផ្នែកគ្រប់គ្រងបញ្ជូន ត្រឡប់មកកាន់ផ្នែកហិរញ្ញវត្ថុវិញ ដើម្បីផ្នែកហិរញ្ញវត្ថុចេញជាសាច់ប្រាក់ជូនគណនេយ្យករយកទៅប្រើប្រាស់។ ដើម្បីបំពេញតួនាទីក្នុងការជួយដល់ការអភិវឌ្ឍដោយផ្តល់នូវយុទ្ធសាស្ត្រចំណាយទាំងមូល ក្រុមហ៊ុន ស៊ី.ភី. មានគោលនយោបាយសំខាន់ៗដែលអាចធ្វើឱ្យអាជីវកម្មប្រកបដោយនិរន្តរ៍ភាព។ ទោះជាយ៉ាងណាមិញរាល់ការចំណាយទាំងនេះផងដែរ គឺត្រូវបានក្រុមគណនេយ្យករ និងក្រុមការងារដែលមាន ចំណេះដឹងលើផ្នែកគ្រប់គ្រង និងការចំណាយដែលមានលក្ខណៈស្តង់ដារបានរៀបចំ ស្នើសុំចុះបញ្ជី តាមដានរាល់ចំណាយដោយមានប្រើប្រាស់ឯកសារកត់ត្រាក្នុងបញ្ជីបញ្ចេញបញ្ចូលដែលមានស្តុកទុកនៅក្នុង ក្រុមហ៊ុនហើយធ្វើទៅតាមរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន។ មិនត្រឹមតែប៉ុណ្ណោះក្រុមហ៊ុនក៏មាន ការយកចិត្ត ទុកដាក់ចំពោះការបង្វឹកនូវបុគ្គលិកថ្មីៗដើម្បីជៀសវាងការកើតឡើងនូវកំហុសជាអចេតនា។ ដោយយោងតាមសម្តីរបស់គណៈគ្រប់គ្រងរាល់ចំណាយរបស់ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ប្រសិនជាត្រូវការទិញសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងក្រុមហ៊ុន គឺលោកត្រូវរៀបចំស្នើសុំថវិកាទុកសម្រាប់ គម្រោងចំណាយ ប្រចាំខែរួចបានធ្វើសំណើរឡើងតាមក្រោយក្នុងគោលបំណងត្រៀមទុកសម្រាប់ខែបន្ទាប់ទៀត។ រីឯចំណាយដែលធំៗ គឺក្រុមហ៊ុនមានគោលការណ៍ផ្សេងទៀតក្នុងការៀបចំចំណាយនោះដោយស្នើទៅក្រៅ ប្រទេសដើម្បីឡើងជាសំណើរដកលុយទិញសម្ភារៈផ្សេងៗប្រើប្រាស់ក្នុងក្រុមហ៊ុន។

**៣.២.៣ ការស្នើសុំ និងការអនុម័ត**

នៅក្នុងក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់ ដំណើរការស្នើសុំ និងអនុម័តលើគម្រោងថវិកា (**Budget Proposal & Approval Process**) គឺជាដំណើរការសំខាន់ ដើម្បីធានាថាការចំណាយមានការគ្រប់គ្រងល្អ និងសមស្របនឹងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន។ ការស្នើសុំ និងការអនុម័ត គឺត្រូវបានអនុវត្តក្នុងការបញ្ជូនសំណើពីបុគ្គលឬពីផ្នែកមួយទៅកាន់ផ្នែកមួយដែលទទួលខុសត្រូវក្នុងការអនុម័តនូវសំណើនិងការងារផ្សេងៗ។

**១. ដំណើរការស្នើសុំថវិកា (Budget Proposal Process)**

ការស្នើសុំថវិកា អាចមកពីផ្នែកផ្សេងៗនៅក្នុងក្រុមហ៊ុនដូចជា ផ្នែកផលិតកម្ម (Production), ផ្នែកទីផ្សារ (Marketing), ផ្នែកលក់ (Sales), និងផ្នែកផ្សេងៗទៀត។ ដំណើរការមានដូចខាងក្រោម៖

**១.១ ការរៀបចំសំណើសុំថវិកា (Preparation of Budget Proposal)**

ផ្នែកដែលត្រូវការថវិកា (Requesting Department) បង្កើតសំណើសុំដោយបញ្ជាក់៖

- គោលបំណងនៃការចំណាយ
- ចំនួនថវិកាដែលត្រូវការ
- ប្រភពថវិកា (Internal Budget / External Funding)

**១.២ ការដាក់ស្នើសុំថវិកា (Submission of Budget Request)**

- បញ្ជូនសំណើសុំទៅផ្នែកហិរញ្ញវត្ថុ (Finance Department)
- ផ្នែកហិរញ្ញវត្ថុធ្វើការត្រួតពិនិត្យ និងវាយតម្លៃលើ
  - តម្លៃ និងលទ្ធភាពចំណាយ

- ប្រភពថវិកា និងផលប៉ះពាល់លើស្ថិរភាពហិរញ្ញវត្ថុ
- តើសំណើសុំនេះសមរម្យនឹងការគ្រោងទុករបស់ក្រុមហ៊ុន ឬអត់

**២. ដំណើរការការអនុម័តថវិកា (Budget Approval Process)**

បន្ទាប់ពីសំណើសុំថវិកាត្រូវបានដាក់ស្នើ ការអនុម័តអាចត្រូវការរយៈពេលខ្លី ឬយូរ ប្រសិនបើគម្រោងធំ និងមានការចំណាយច្រើន។

**២.១ ការវាយតម្លៃនិងអនុម័តពីផ្នែកហិរញ្ញវត្ថុ (Finance Department Review & Approval)**

- ពិនិត្យសំណើសុំថវិកាទាំងស្រុង
- វាយតម្លៃលទ្ធភាពចំណាយ និងប្រៀបធៀបទៅនឹងចំណូលប៉ាន់ស្មានប្រចាំឆ្នាំ
- ផ្ញើរបាយការណ៍ដល់ថ្នាក់គ្រប់គ្រង

**២.២ ការអនុម័តលំដាប់ថ្នាក់គ្រប់គ្រង (Management Approval)**

ការអនុម័តគឺអាស្រ័យលើទំហំ និងសារៈសំខាន់នៃគម្រោង៖

ឧទាហរណ៍ថាៈ

- ថវិកាចំណាយតូច (< $10,000 USD) → អនុម័តដោយប្រធានផ្នែក (Department Head)
- ថវិកាចំណាយមធ្យម ($10,000 - $50,000 USD) → អនុម័តដោយ GM (General Manager)
- ថវិកាចំណាយធំ (> $50,000 USD) → ត្រូវមានការអនុម័តពី CEO ឬក្រុមប្រឹក្សាភិបាល BOD




**លំហូរសញ្ញាលើការស្នើសុំគម្រោងថវិកា**

**៣.២.៤ ការចាត់ចែងទៅលើចំណាយ**

បន្ទាប់ពីគម្រោងថវិកាត្រូវបានអនុម័ត ផ្នែកហិរញ្ញវត្ថុនឹងបែងចែកថវិកាទៅផ្នែកដែលបានស្នើសុំតាមដំណាក់កាលដែលត្រូវប្រើប្រាស់ ហើយក្រុមហ៊ុនក៏មានបង្កើតការតាមដាន និងបញ្ជាក់ពីវិធីសាស្ត្រចំណាយមានការចាត់ចែងដំណើរការប្រតិបត្តិការយ៉ាងប្រកដប្រជា។ ក្រុមហ៊ុនអនុវត្តយុទ្ធសាស្ត្រការគ្រប់គ្រងហិរញ្ញវត្ថុដោយមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការចាត់ចែងហានិភ័យ ដើម្បីធានាថាការចំណាយត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព និងអាចបំពេញគោលដៅអាជីវកម្មបាន។

ក្រុមប្រឹក្សាភិបាល និងគណៈកម្មការអនុវត្តការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុ ដើម្បីធានាការចំណាយមានភាពស្របច្បាប់ និងបំពេញគោលដៅនានា។ ក្រុមហ៊ុនក៏មានប្រព័ន្ធត្រួតពិនិត្យសេចក្តីរាយការណ៍ហិរញ្ញវត្ថុដើម្បីធានាថាតម្លៃសេវាកម្ម និងផលិតផលមានតម្លៃសមរម្យ ស្របតាមគោលការណ៍គ្រប់គ្រងសិទ្ធិប្រកបដោយភាពស្មើភាព។

បន្ថែមពីនេះ ក្រុមហ៊ុនអនុវត្តគោលនយោបាយប្រកបដោយចក្ខុវិស័យបរិស្ថាន និងសង្គម ដោយអភិវឌ្ឍគម្រោងដែលផ្តោតលើការប្រកបដោយចីរភាព។ ក្រុមហ៊ុនបានកំណត់គោលដៅដល់ឆ្នាំ 2030 ដែលរួមមានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ការគ្រប់គ្រងកាកសំណល់ និងការចិញ្ចឹមជីវិតសង្គម។ ការអនុវត្តគម្រោងថវិកាគឺស្របតាមគោលដៅនោះ ដើម្បីធានាថាការប្រតិបត្តិមានប្រសិទ្ធភាព និងទទួលផលវិបុល។

**៣.២.៥ ការត្រួតពិនិត្យលើផែនការ និងការអនុវត្តន៍**

ការត្រួតពិនិត្យលើការអនុវត្តន៍គម្រោង ជាកាតព្វកិច្ចរបស់ផ្នែកគណនេយ្យ និងប្រធានផ្នែក ក្រោយពេលបណ្តាផ្នែកនីមួយៗបានប្រើប្រាស់ចំណាយទាំងនោះ ដែលបានស្នើក្នុងគម្រោងថវិកាប្រចាំខែ ឬប្រចាំឆ្នាំ។ ដើម្បីឱ្យការត្រួតពិនិត្យលើការអនុវត្តន៍គម្រោងថវិកាមានភាពងាយស្រួល និងមានព័ត៌មានច្បាស់លាស់ ក្រុមហ៊ុនបានប្រើប្រាស់នូវនីតិវិធីដូចខាងក្រោម៖

- ប្រធានផ្នែកត្រូវត្រួតពិនិត្យប្រតិបត្តិការចំណាយនៅក្នុងផ្នែកប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ
- គ្រប់បណ្តាផ្នែកទាំងអស់ត្រូវដាក់របាយការណ៍ចំណាយ (Expense Reporting) មកកាន់ផ្នែកគណនេយ្យ ស្របពេលជាមួយនឹងការស្នើសុំគម្រោងថ្មី ចាប់ពីថ្ងៃទី20 ដល់ថ្ងៃទី30 នៃខែនីមួយៗ។
- គម្រោងថវិកាដែលត្រូវបង្ហាញជាលក្ខណៈប្រៀបធៀប រវាងការស្នើសុំខែមុន ការប្រើប្រាស់ខែមុន ចំនួនបរិមាណនៅសល់ តម្រូវការខែបន្ទាប់ និងត្រូវមានឯកសារភ្ជាប់ (វិក័យបត្រចំណាយដែលបានប្រើប្រាស់) ផ្សេងទៀតប្រសិនបើមាន។
- ករណីចំណាយមានចំនួនច្រើន ឬពុំមានភាពត្រឹមត្រូវ ខ្វះព័ត៌មានផ្នែកគណនេយ្យអាចធ្វើការអញ្ជើញផ្នែកស្នើសុំ មកធ្វើការពិនិត្យឡើងវិញតាមការចាំបាច់ជាក់ស្តែង។
- ករណីមានចំណាយបន្ថែមដែលមានហេតុផលច្បាស់លាស់ និងសមស្របតាមតម្រូវការជាក់ស្តែង ត្រូវមានការបែងចែកថវិកាបន្ថែម ។
- ក្រុមហ៊ុនអាចមាន Internal Audit ឬ External Audit ធ្វើការត្រួតពិនិត្យដើម្បីធានាថាការចំណាយមានភាពស្របច្បាប់និងប្រសិទ្ធភាព។

## ៣.៣ អត្ថប្រយោជន៍ក្នុងដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់

ក្នុងបរិបទសេដ្ឋកិច្ចបច្ចុប្បន្ន ការគ្រប់គ្រងហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាពជាធាតុមួយសំខាន់សម្រាប់ភាពជោគជ័យ។ ក្នុងចំណោមវិធានការគ្រប់គ្រងនានា ការរៀបចំគម្រោងថវិកាត្រូវបានចាត់ទុកជាឧបករណ៍សំខាន់មួយដែលអាចជួយឱ្យក្រុមហ៊ុនសម្រេចគោលដៅរបស់ខ្លួនបានយ៉ាងច្បាស់លាស់។ ដំណើរការនេះមិនត្រឹមតែមានប្រយោជន៍ដល់ក្រុមហ៊ុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់នូវភាពងាយស្រួលទៅដល់មជ្ឈដ្ឋានខាងក្រៅដូចជាវិនិយោគិន អតិថិជន និងសហគមន៍ជុំវិញផងដែរ។ ដូច្នេះការយល់ដឹងអំពីដំណើរការរៀបចំគម្រោងថវិកាគឺមានសារៈសំខាន់ដើម្បីធានាបាននូវការអភិវឌ្ឍន៍របស់អង្គភាពស្ថិតក្នុងទិសដៅប្រកបដោយចីរភាព។

### ៣.៣.១ អត្ថប្រយោជន៍ចំពោះក្រុមហ៊ុន

- ដឹងពីការគ្រប់គ្រងលំហូរសាច់ប្រាក់
- ងាយស្រួលក្នុងការប្រៀបធៀបប្រតិបត្តិការក្នុងការិយថ្មីទៅនឹងការិយចាស់ និងការរៀបចំគម្រោងថវិកាសម្រាប់ឆ្នាំថ្មី
- ជាសូចនាករដែលជម្រុញឱ្យក្រុមហ៊ុនឈានទៅដល់ការសម្រេចគោលដៅដែលគ្រោងទុក។
- ដឹងពីបញ្ហាប្រឈម និងដោះស្រាយទាន់ពេលវេលា ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់អង្គភាពដែលបានកំណត់ទុកសម្រាប់ពេលអនាគត
- ផ្តល់នូវព័ត៌មានចាំបាច់សម្រាប់ជាមធ្យោបាយ ក្នុងការគ្រប់គ្រងបញ្ហាប្រឈមដែលមិនបានរំពឹងទុក និងការរកប្រាក់ចំណេញ
- ធ្វើឱ្យការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុរបស់អង្គភាពមានភាពរឹងមាំ និងមានភាពច្បាស់លាស់
- ងាយស្រួលឱ្យម្ចាស់ក្រុមហ៊ុនសម្រេចចិត្តក្នុងការប្រើប្រាស់ថវិកាយ៉ាងមានប្រសិទ្ធភាពខ្ពស់

**ក. អត្ថប្រយោជន៍ចំពោះម្ចាស់ក្រុមហ៊ុន**

- បានដឹងពីប្រភពចំណូល ចំណាយ និងចំណេញ ដែលក្រុមហ៊ុនអាចរកបាន នឹងទទួលបាននៅពេលណាមួយ
- អាចធ្វើការព្យាករណ៍ពីតម្រូវការហិរញ្ញវត្ថុសម្រាប់ប្រើប្រាស់នាពេលអនាគត
- ជួយក្នុងការសម្រេចចិត្តមុន នឹងធ្វើការចំណាយ ឬកម្ចីធនាគា ដើម្បីអភិវឌ្ឍក្រុមហ៊ុនបន្ថែមទៀត
- ជាមូលដ្ឋានសម្រាប់វាយតម្លៃលើការអនុវត្ត តាមរយៈការប្រៀបធៀបលទ្ធផលហិរញ្ញវត្ថុជាក់ស្តែងទៅនឹងតួលេខ កំណត់ភាពខ្លាំងនិងភាពខ្សោយ ដើម្បីធ្វើការកែតម្រូវការអនុវត្តគម្រោងថវិកា
- គ្រប់គ្រងហានិភ័យលើការប្រើប្រាស់ចំណាយខុសគោលដៅ
- បង្កើតបាននូវគោលនយោបាយហិរញ្ញវត្ថុសម្រាប់អនុវត្តក្នុងពេលបច្ចុប្បន្ន និងអនាគត។

**ខ. អត្ថប្រយោជន៍ចំពោះបណ្តាផ្នែកក្នុងអង្គភាព**

- តាមរយៈដំណើរការនេះ បុគ្គលិកមានឱកាសប្រាស្រ័យទាក់ទង និងសហការជាមួយសមាជិកមកពីផ្នែកផ្សេងៗនៃក្រុមហ៊ុន និងជួយជម្រុញការងារជាក្រុម
- ពួកគេទទួលបានការបង្ហាញពីគំនិត និងការអនុវត្តផ្នែកហិរញ្ញវត្ថុ ពង្រឹងជំនាញ និងចំណេះដឹងរបស់ពួកគេ ដែលអាចមានប្រយោជន៍សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ
- លើកទឹកចិត្តសមាជិកបុគ្គលិកឱ្យចូលរួមជាគំនិតនិងយោបល់សម្រាប់ការកែលម្អការគ្របគ្រងហិរញ្ញ វត្ថុ និងប្រសិទ្ធភាពប្រតិបត្តិការរបស់ក្រុមហ៊ុន។
- សមាជិកបុគ្គលិករួមចំណែកក្នុងការអភិវឌ្ឍថវិកាដែលទទួលបានជោគជ័យ និងសម្រេចបាននូវគោលដៅថវិកា ពួកគេនឹងមានអារម្មណ៍អបអរនូវសមិទ្ធផល និងមោទនភាពក្នុងការងាររបស់ពួកគេ

- អនុញ្ញាតឱ្យសមាជិកបុគ្គលិកអនុវត្តគម្រោងថវិកា យល់ច្បាស់អំពីគោលដៅរបស់ក្រុមហ៊ុន កាន់តែ ទូលំទូលាយ
- បុគ្គលិកអនុវត្តគម្រោងថវិកាជ្រួតជ្រាបនូវវិន័យក្នុងការស្វែងរកចំណូល ចំណាយផ្សេងៗ
- យល់ដឹងអំពីតួនាទីរបស់ពួកគេ ក្នុងការចូលរួមចំណែកដល់ការសម្រេចបាននូវគោលដៅទាំងនោះ ព្រមទាំងជម្រុញទឹកចិត្តនៃគោលបំណងរបស់បុគ្គលិក ជាមួយនឹងបេសកកម្មរបស់ក្រុមហ៊ុនឱ្យកាន់តែប្រសើរ។

**៣.៣.២ អត្ថប្រយោជន៍ចំពោះមជ្ឈដ្ឋានខាងក្រៅ**

- **អ្នកផ្គត់ផ្គង់ និងដៃគូអាជីវកម្ម៖** ការរៀបចំថវិកាធ្វើឲ្យ CP Cambodia អាចបញ្ជាក់ការបញ្ជាទិញជាមុនសម្រាប់វត្ថុធាតុដើម និងសេវាកម្មផ្សេងៗ។ វាបង្កើតឱកាសសម្រាប់ដៃគូផ្គត់ផ្គង់មានការធានាច្បាស់លាស់អំពីបរិមាណ និងពេលវេលាបញ្ជាទិញ។ អ្នកផ្គត់ផ្គង់អាចរៀបចំផលិតផល ឬសេវាកម្មឲ្យទាន់ពេលតាមតម្រូវការរបស់ក្រុមហ៊ុនបានល្អជាងមុន។
- **អតិថិជន៖** គម្រោងថវិកាដែលរៀបចំបានល្អជួយធានាថាក្រុមហ៊ុនអាចផលិត និងផ្គត់ផ្គង់ផលិតផលបានគ្រប់គ្រាន់ និងទាន់ពេល ដើម្បីបំពេញតម្រូវការរបស់អតិថិជន។ វាជួយបង្កើនភាពទុកចិត្តរបស់អតិថិជន ចំពោះផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន។
- **អ្នកវិនិយោគិន និងស្ថាប័នហិរញ្ញវត្ថុ៖** ថវិកាដែលបានរៀបចំយ៉ាងជាក់ស្តែងនឹងបង្ហាញថាក្រុមហ៊ុនមានការគ្រប់គ្រងល្អ និងមានសមត្ថភាពទទួលខុសត្រូវ ហើយនេះជាកត្តាដ៏ល្អក្នុងការទាក់ទាញអ្នកវិនិយោគទុន ឬទទួលបានកម្ចីពីធនាគារ។
- **មជ្ឈដ្ឋានសហគមន៍៖** នៅជុំវិញតំបន់ផលិតកម្ម ការរៀបចំថវិកាធ្វើឲ្យមានការចំណាយលើសកម្មភាពទទួលខុសត្រូវក្នុងសង្គម និងការអភិវឌ្ឍសហគមន៍ដូចជា ការចូលរួមបរិច្ចាគ ការរួមចំណែកអភិវឌ្ឍសាលារៀន សុខាភិបាល និងបរិស្ថាន។ វាបង្ហាញពីភាពទទួលខុសត្រូវ និងភាពជាដៃគូរបស់ក្រុមហ៊ុនជាមួយសហគមន៍។
- **រដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ៖** ការរៀបចំថវិកាត្រឹមត្រូវជួយឲ្យ CP Cambodia អាចគ្រប់គ្រងការបង់ពន្ធ និងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុត្រឹមត្រូវ។ វាជួយបង្កើនភាពជឿជាក់ពីរដ្ឋាភិបាល និងលើកកម្ពស់ភាពស្របច្បាប់របស់អាជីវកម្ម។

# ជំពូកទី ៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ គឺជាដំណើរការសំខាន់មួយក្នុងការប៉ាន់ប្រមាណ និងវាយតម្លៃលើការអនុវត្តការងាររបស់ក្រុមហ៊ុន ជាពិសេសក្នុងការរៀបចំគម្រោងថវិកា។ វាជួយបង្ហាញពីសមត្ថភាព និងប្រសិទ្ធភាពការងារ បណ្តាលឱ្យក្រុមហ៊ុនអាចកំណត់បានថា តើតំបន់ណាដែលគួរអភិវឌ្ឍបន្ថែម និងតំបន់ណាដែលត្រូវកែលម្អ។ បន្ទាប់ពីក្រុមយើងបានអនុវត្តការស្រាវជ្រាវ វាស់វែង និងវាយតម្លៃលើដំណើរការរៀបចំគម្រោងថវិកា ផែនការយុទ្ធសាស្ត្រ និងនីតិវិធីរបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់ (C.P. CAMBODIA CO., LTD) ហើយបានរកឃើញចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួន ដែលអាចជាជំហានសំខាន់សម្រាប់ការកែលម្អ និងអភិវឌ្ឍអនាគតរបស់ក្រុមហ៊ុន។

## ៤.១ ការវិភាគលើចំណុចខ្លាំង

ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ជាក្រុមហ៊ុនដែលមានភាពជឿនលឿន និងមានការកែច្នៃយ៉ាងប្រណិតទាក់ទងទៅនឹងការផលិតចំណីសត្វ ការចិញ្ចឹមសត្វ និងការផលិតចំណីអាហារ ដែលមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល។ តាមរយៈការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំកន្លងមក ក្រុមហ៊ុននេះមានចំណុចខ្លាំងទៅលើការគ្រប់គ្រងថវិកាដែលគួរយកមកសិក្សាដូចខាងក្រោម៖

- ការរៀបចំគម្រោងថវិកាក្នុងក្រុមហ៊ុនត្រូវបានអនុវត្តតាមនីតិវិធីច្បាស់លាស់ ដែលរួមមានការរៀបចំផែនការ ការព្យាករណ៍ថវិកា ការត្រួតពិនិត្យនិងការអនុម័ត ដោយផ្អែកលើសកម្មភាពដែលត្រូវអនុវត្ត និងថវិកាដែលត្រូវបានកំណត់សម្រាប់នីតិវិធីរៀងៗខ្លួន។
- ក្រុមហ៊ុនមានស្តង់ដារក្នុងការរៀបចំផែនការចំណាយដោយធ្វើការចាត់ថ្នាក់ជាជម្រើសស្តង់ដារ និងប៉ាន់ស្មានថវិកាដោយប្រើវិធីសាស្ត្រដែលច្បាស់លាស់ ដើម្បីធានាថាការចំណាយនីមួយៗស្របទៅតាមគោលនយោបាយ និងអាចវាយតម្លៃសកម្មភាពបានយ៉ាងលម្អិត។
- ការចំណាយគ្រប់ប្រភេទត្រូវបានគ្រប់គ្រងយ៉ាងម៉ត់ចត់ តាមរយៈការកត់ត្រាបញ្ជីចំណាយប្រចាំថ្ងៃ និងប្រចាំខែ ហើយការចំណាយណាដែលគ្មានគម្រោងទុកជាមុន នឹងត្រូវបានទប់ស្កាត់ដោយប្រព័ន្ធស្នើសុំ និងវាយតម្លៃយ៉ាងតឹងរឹង។
- ប្រព័ន្ធគណនេយ្យរបស់ក្រុមហ៊ុនមានលក្ខណៈស្តង់ដារអន្តរជាតិដែលអាចទុកចិត្តបាន និងធានាថាការកត់ត្រាហិរញ្ញវត្ថុមានភាពត្រឹមត្រូវ ច្បាស់លាស់ និងគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុជាទូទៅ។
- ក្រុមការងារ និងគណនេយ្យករមានជំនាញខ្ពស់ក្នុងការត្រួតពិនិត្យការចំណាយ យល់ដឹងលើការគ្រប់គ្រងហានិភ័យ និងមានដំណោះស្រាយសម្រាប់បញ្ហាអនាគត ដែលធ្វើឱ្យការអនុវត្តគម្រោងទៅតាមផែនការរលូន មានប្រសិទ្ធភាព ធ្វើឱ្យក្រុមហ៊ុនអាចប្រើប្រាស់ពេលវេលាដោយមានតម្លាភាព។
- មានការទំនាក់ទំនង និងសហការរវាងផ្នែកនីមួយៗក្នុងការរៀបចំថវិកា ក្នុងការធានាថាការចំណាយ និងសកម្មភាពអាជីវកម្មប្រតិបត្តិទៅតាមគោលនយោបាយរួម ដោយបង្កើនការយល់ដឹងព្រមគ្នា ការសម្របសម្រួល និងសមិទ្ធផលរួមក្នុងការអភិវឌ្ឍន៍ក្រុមហ៊ុន។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ការអនុវត្តការងារ ទោះបីជាលទ្ធផលល្អយ៉ាងណាក៏ដោយ នៅតែអាចមានចន្លោះខ្វះខាតតែងតែលេចឡើងដូចគ្នា ក្នុងនោះការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់ ក៏នៅមានចំណុចខ្សោយមួយចំនួនដែលបង្កឱ្យមានហានិភ័យក្នុងដំណើរការរៀបចំគម្រោងថវិកាដូចជា៖

- **ការប្រមូលព័ត៌មានយឺតយ៉ាវពីផ្នែកមួយចំនួន៖** ការប្រមូលព័ត៌មានពីផ្នែកមួយចំនួនមិនទាន់ពេល គឺជាឧបសគ្គសំខាន់មួយក្នុងការរៀបចំផែនការថវិកាឱ្យទាន់ពេលវេលា និងមានភាពត្រឹមត្រូវខ្ពស់។ ទោះបីមានកាលបរិច្ឆេទកំណត់យ៉ាងណាក៏ដោយ ការយឺតយ៉ាវនេះធ្វើឱ្យមានការពន្យាពេលក្នុងការអនុម័តគម្រោង និងបាត់បង់ភាពជាក់លាក់ក្នុងការអនុវត្ត។
- **ការព្យាករណ៍តម្លៃទីផ្សារមិនបានត្រឹមត្រូវ និងកង្វះព័ត៌មាន៖** ក្រុមហ៊ុនមានការប្រឈមជាមួយការខ្វះថវិកា ដោយសារការត្រួតពិនិត្យលើតម្លៃនៃចំណាយមិនបានត្រឹមត្រូវ និងបញ្ហាកង្វះទិន្នន័យសំខាន់ៗក្នុងការរៀបចំផែនការចំណាយ។ ការខ្វះពត៌មានគ្រប់គ្រាន់នាំឱ្យមានការចំណាយខុសពីគោលដៅ និងស្ថិតិនៃថវិកាដែលបង្កប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តការងារ។
- **ឧបទ្ទវហេតុ និងការត្រៀមថវិកាបម្រុង៖** ដោយសារក្រុមហ៊ុនផលិតកម្មដែលអាស្រ័យទៅលើការធ្វើដំណើរ និងការបញ្ជូនផលិតផលតាមផ្លូវសាធារណៈ ការប្រើប្រាស់គ្រឿងចក្រ និងបច្ចេកវិទ្យាទំនើបតែងតែជួបប្រទះនឹងឧបទ្ទវហេតុដូចជា គ្រោះថ្នាក់ចរាចរណ៍ ការខូចខាតនៃម៉ាស៊ីន និងឧបករណ៍ផ្សេងៗ។ បញ្ហាទាំងនេះនាំឱ្យកើតមានការចំណាយឥតព្រាងទុក ដែលក្រុមហ៊ុនមិនមានកញ្ចប់ថវិកាបម្រុងគ្រប់គ្រាន់ដើម្បីប្រឈម។ លើសពីនេះការវាយតម្លៃមិនត្រឹមត្រូវលើការចំណាយបន្ទាន់ៗនៅទីផ្សារផង គឺធ្វើឱ្យការប្រើប្រាស់ថវិកាមិនមានភាពតុល្យភាព ហើយបណ្តាលឱ្យគម្រោងមានការពន្យាពេល ឬបាត់បង់ទិសដៅអាជីវកម្ម។

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានចំណាយពេលសិក្សាលើប្រធានបទ «ដំណើរការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់» (C.P. CAMBODIA CO., LTD) និងបានធ្វើការវិភាគពីបញ្ហាជាក់ស្តែង បូករួមជាមួយការប៉ាន់ប្រមាណអំពីអត្ថប្រយោជន៍ និងបញ្ហាដែលកើតមានរួចមកហើយអាចឱ្យយើងឃើញថា ការរៀបចំគម្រោងថវិកា គឺជាឧបករណ៍សំខាន់មួយសម្រាប់ជួយដល់ការគ្រប់គ្រង និងការធ្វើផែនការជាប្រព័ន្ធនៅក្នុងក្រុមហ៊ុន។ វាធ្វើឱ្យក្រុមហ៊ុនអាចកំណត់សកម្មភាពប្រសើរបំផុត សម្រេចបានការបែងចែកធនធាន និងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធិភាព។ ការរៀបចំថវិកាក៏ជួយផ្តល់ភាពច្បាស់លាស់ក្នុងការធ្វើផែនការអនាគត ដឹកនាំលំហូរសាច់ប្រាក់។ ទោះបីវាមិនអាចធានាថាក្រុមហ៊ុននឹងជោគជ័យបាន ១០០% ក៏ដោយ ប៉ុន្តែវាជាសមាសធាតុមួយដ៏សំខាន់ ដែលជាទីប្រឹក្សាដល់ភាពជោគជ័យទាំងមូលរបស់អង្គភាព។

យោងទៅតាមទ្រឹស្តីនានា និងលទ្ធផលនៃការសិក្សាស្រាវជ្រាវផ្សេងៗដែលទាក់ទងជាមួយការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ស៊ី ភី ខេមបូឌា យើងឃើញថាក្រុមហ៊ុនពិតជាមានកិច្ចសហការ និងការប្រាស័យទាក់ទងគ្នារវាងភាគីពាក់ព័ន្ធបានល្អ និងមានការត្រួតពិនិត្យត្រឹមត្រូវ ដែលធ្វើឱ្យដំណើរការនៃគម្រោងប្រព្រឹត្តទៅដោយរលូន ត្រឹមត្រូវ និងទទួលលទ្ធផលវិជ្ជមាន។ ហើយក្រុមហ៊ុន ស៊ី ភី ខេមបូឌា ជាក្រុមហ៊ុនមួយដែលមានការគាំទ្រពីអតិថិជនទាំងក្នុងនិងក្រៅប្រទេសយ៉ាងច្រើន ជាពិសេសពីសំណាក់ប្រជាកសិករកម្ពុជាតែម្តង។ តួយ៉ាង បើទោះបីជាក្រុមហ៊ុននេះមានសក្តានុភាពខ្លាំងហើយក្តី ក៏ក្រុមហ៊ុននៅតែអភិវឌ្ឍខ្លួនទាំងក្នុងនិងក្រៅកាន់តែប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុករបស់អតិថិជន ដែលនាំមកនូវការផលិត និងការកែច្នៃឥតឈប់ឈរសម្រាប់អតិថិជននិងក្រុមហ៊ុនផ្ទាល់ផងដែរ។

នៅក្នុងពេលបច្ចុប្បន្ននេះ នៅពេលដែលបរិយាកាសការប្រកួតប្រជែងមានល្បឿនខ្ពស់ និងការផ្លាស់ប្តូរមានយ៉ាងឆាប់រហ័ស ការរៀបចំគម្រោងថវិកាពិតជាផ្នែកមួយដ៏សំខាន់សម្រាប់ភាពរីកចម្រើនរបស់ក្រុមហ៊ុន។ ទោះជាយ៉ាងណា ភាពរីកចម្រើននេះក៏មិនអាចមកដោយគ្មានបញ្ហានោះទេ ពីព្រោះនៅតែមានចំណុចខ្វះខាតមួយចំនួន ដែលប្រសិនបើមិនកែសម្រួលឱ្យទាន់ពេលអាចបង្កផលប៉ះពាល់ដល់ផលប្រយោជន៍របស់ក្រុមហ៊ុនបានផងដែរ។

ជាលទ្ធផលចុងក្រោយ យើងអាចសន្និដ្ឋានបានថា ក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់ ពិតជាមានការរៀបចំគម្រោងថវិកាដែលច្បាស់លាស់ និងប្រកបដោយប្រព័ន្ធគ្រប់គ្រងលើចំណូល ចំណាយ និងធនធានយ៉ាងមានប្រសិទ្ធភាព។ កត្តាទាំងនេះហើយបានជួយឱ្យក្រុមហ៊ុនមានស្ថិរភាព និងអភិវឌ្ឍយ៉ាងរឹងមាំ ទាំងក្នុងការប្រឈមនឹងការផ្លាស់ប្តូរនិងការរីកចម្រើនក្នុងវិស័យអាជីវកម្មរបស់ខ្លួន។ វាបញ្ជាក់ថា ការរៀបចំថវិកាដោយមានគោលបំណងច្បាស់ និងទិសដៅត្រឹមត្រូវ គឺជាគន្លងសំខាន់នៃភាពជោគជ័យរបស់ក្រុមហ៊ុន។

## ៥.២ ការផ្តល់អនុសាសន៍

យោងតាមការសិក្សា និងការវិភាគលើដំណើរការរៀបចំថវិកានាពេលកន្លងមក ក្រុមយើងខ្ញុំបានសង្កេតឃើញនូវចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានមួយចំនួនដែលអាចមានឥទ្ធិពលប៉ះពាល់ដល់ប្រសិទ្ធភាពក្នុងការ

គ្រប់គ្រងផែនការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ជាការចូលរួមរួមចំណែកក្នុងការកែលម្អ និងជួយសម្រួលដំណើរការអភិវឌ្ឍគម្រោងឱ្យកាន់ តែមានលក្ខណៈត្រឹមត្រូវថែមមួយកម្រិតទៀត យើងខ្ញុំសូមអនុញ្ញាតផ្តល់ជាអនុសាសន៍មួយចំនួនដើម្បីជាការស្ថាបនាឱ្យក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់ ឱ្យកាន់តែប្រសើរឡើង៖

- គ្រប់ផ្នែកដែលពាក់ព័ន្ធ គួរតែផ្តោតសំខាន់ទៅលើពេលវេលាក្នុងការប្រគល់ឯកសារ ធ្វើយ៉ាងណាប្រគល់ជូនផ្នែកដែលត្រូវការឱ្យបានមុនកាលបរិច្ឆេទកំណត់ ដើម្បីឱ្យអ្នកទទួលឯកសារមានពេលគ្រប់គ្រាន់ ក្នុងការត្រួតពិនិត្យលើគម្រោងឱ្យបានស៊ីជម្រៅជៀសវាងការទទួលយកព័ត៌មានខុសទៅប្រើប្រាស់ក្នុងគម្រោង។ លើសពីនេះទៅទៀតគ្រប់បណ្តាផ្នែក ក៏គួរតែយកចិត្តទុកដាក់លើទិន្នន័យ ឬព័ត៌មានដែលត្រូវប្រគល់ជូនផ្នែកទទួលគម្រោង ឱ្យបានច្បាស់លាស់ក្នុងន័យពន្លឿនពេលត្រួតពិនិត្យបានយ៉ាងឆាប់រហ័ស និងជាហេតុផលមួយដើម្បីសម្រួលពេលវេលា ក្នុងការរៀបចំគម្រោងថវិកាប្រកបដោយប្រសិទ្ធភាព និងសមស្របទៅតាម ផែនការដែលត្រូវអនុវត្ត។
- ទន្ទឹមនឹងការខ្វះព័ត៌មានពាក់ព័ន្ធនឹងតម្លៃទីផ្សារ និងសេដ្ឋកិច្ច ជារឿយៗបានជាហេតុបណ្តាលឱ្យការព្យាករណ៍ចំណាយមិនត្រឹមត្រូវ ក្រុមហ៊ុនអាចពិចារណាចំពោះការបង្កើតក្រុមការងារពិសេសមួយ ដែលមានជំនាញផ្នែកវិភាគទីផ្សារ និងទិន្នន័យសេដ្ឋកិច្ច។ ក្រុមនេះអាចប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាទំនើប និងឧបករណ៍ព្យាករណ៍ AI ដើម្បីជួយឱ្យការរៀបចំផែនការហិរញ្ញវត្ថុផ្អែកលើស្ថិតិ និងទិន្នន័យប្រកបដោយភាពជាក់លាក់ និងទាន់សម័យ។ វានឹងជួយកាត់បន្ថយហានិភ័យក្នុងការប្រើប្រាស់ធនធាន ហើយជម្រុញការធ្វើសេចក្តីសម្រេចឱ្យមានភាពច្បាស់លាស់ប្រកបដោយទិសដៅ។
- ក្រុមហ៊ុនគួរតែបង្កើតផ្នែកថវិកាច្បាស់លាស់សម្រាប់បម្រុងក្នុងករណីបន្ទាន់ ដោយកំណត់ជាភាគរយច្បាស់លាស់ពីថវិកាចំណាយសរុប។ ការធ្វើការវាយតម្លៃហានិភ័យប្រចាំឆ្នាំ ឬរៀងរាល់ឆមាស នឹងជួយកំណត់អំពីស្ថានភាពណាដែលអាចប៉ះពាល់ដល់ថវិកាបច្ចុប្បន្ន និងអនាគត។ អ្នកគ្រប់គ្រងគួរតែចាត់ចែងឱ្យមានការត្រៀមបច្ចេកទេសសម្រាប់ប្រតិបត្តិការបន្ទាន់ ព្រមទាំងការរក្សាជម្រើសផ្គត់ផ្គង់បន្ថែម និងចំណាយបន្តិចសមស្រប។ ក្រុមហ៊ុនមួយដែលមានការត្រៀមល្អសម្រាប់ឧបទ្ទវហេតុ នឹងអាចស្តារភាពជឿជាក់របស់អតិថិជន និងបន្តប្រតិបត្តិការបានជាប់លាប់។

# ឯកសារយោង


Cambonomist. (2019, June 10). *នៅពីក្រោយភាពជោគជ័យ របស់មហាសេដ្ឋីលេខ១ របស់ថៃ ម្ចាស់ក្រុមហ៊ុន* CP Group. Retrieved from https://cambonomist.com/news/behind-successful-story-of-dhanin-chearavanont-/

Fish Information Services and Seafood Media Group. (2008). *Charoen Pokphand Group - Headquarters*. Retrieved from https://seafood.media/fis/companies/details.asp?l=e&company_id=158150

The phnom penh post. (2023, April 12). *Commerce minister visits CP food processing factory in Kampot*. Retrieved from https://www.phnompenhpost.com/business/commerce-minister-visits-cp-food-processing-factory-kampot

Oknha News. (2021, May 15). *មកស្គាល់ក្រុមហ៊ុន ស៊ី.ភី.កម្ពុជា ដែលកំពុងឈរជើងលើវិស័យផលិតកម្មសត្វល្បី ឈ្មោះបោះទុនវិនិយោគប្រមាណ ៦៧,៤ លានដុល្លារ*. Retrieved from https://www.oknha.news/business/22646

CP Cambodia. (2020, March 10). About us. Retrieved from https://www.cpcambodia.net/about-us/

Fresh News Asia. (2024, May 18). *ឧបនាយករដ្ឋមន្ត្រី ហង់ជួន ណារ៉ុន ចុះទស្សនកិច្ចនៅរោងចក្រកែច្នៃផលិតផលអាហារ និងបំលែងសាច់មាន់ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់ ដើម្បីលើកកម្ពស់ចំណះដឹងពីអាហារសុវត្ថិភាព*. Retrieved from https://m.freshnewsasia.com/index.php/en/freshnewsplus/341452-2024-05-18-09-58-54.html

CP World Wide. (2019, February 01). *Management Structure*. Retrieved from https://www.cpfworldwide.com/en/about/leadership

CP Group Global. (2024, August 21). *CP Group Releases 2023 Sustainability Report*. Retrieved from: https://www.cpgroupglobal.com/en/newsroom/news/643/cp-group-releases-2023-sustainability-report-focusing-on-developing-the-new-generation-and-driving-collaboration-across-all-sectors-to-embrace-the-50-world

Thorn Sreypich, Chan Punleu Reaksmey, Gech Houng, Auet Sreynit, Kheang Ravy (2023) Management Cost of CP Cambodia Co.,Ltd. Bachelor thesis, VANDA Institute, Cambodia.

Yorn Somrith, Nuth Sereithy, Chea Chan Nyne, Phon Sophat, Cheoun Chen Eang (2024) The Budget Preparation of C.U.L.M Co.,Ltd. Bachelor thesis, VANDA Institute, Cambodia.

CP Group Global. (2025, January 11). *CP Group 2030 framework and goals*. Retrieved from https://www.cpgroupglobal.com/en/sustainability/sustainability-at-cp-group/cp-group-2030-framework-and-goals

CP Group Global. (2024, August 21). *Compliance*. Retrieved from https://www.cpgroupglobal.com/en/corporate-governance/compliance

# ឧបសម្ព័ន្ធ



TOPIC: MANAGEMENT COST OF
CP CAMBODIA Co.,ltd
B20/581
B20/575
B20/1006
B20/2224
B20/1324
016.277
VIA.PP/2023
PHNOM PENH-2023




Success Career Path
CP Cambodia Co., Ltd.
Intro
Featured
Photos
Posts




FORCE FOR A SUSTAINABLE LIFE
Seeding the Future
CHAROEN POKPHAND GROUP
SUSTAINABILITY REPORT 2019




FUNDAMENTALS
គ្រប់គ្រងគម្រោង
COMPUTER SOFTWARE
SOFTWARE PROJECT MANAGEMENT
COMPLETE PROJECT ON TIME AND ON BUDGET
COMMUNICATE EFFECTIVELY WITH YOUR TEAM
ALIGN PROJECT WITH STRATEGY
BASIC FOR THE REAL WORLD
495.565
P53
VIA.PP/2010
Editions Angkor

**C.P. Cambodia Co., Ltd.**

## និមិត្តសញ្ញាក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់




សំណង់អគារក្រុមហ៊ុន ស៊ី ភី ខេមបូឌា ចំកាត់
អាសយដ្ឋាន: #0227E ផ្លូវជាតិលេខ ៤ ភូមិផ្សារកំបូល សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ